**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2011, 15:52
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានាទាក់ទងនឹងការទទួលយកនូវ**
**កំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ:**
**នួន ជា**
**អៀង សារី**
**អៀង ធីរិទ្ធ**
**ខៀវ សំផន**

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សុវាន
លោក Jacques VERGÈS

# I. សេចក្ដីផ្ដើម

១- ដោយយោងទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំពន្យារពេល[1] សហព្រះរាជអាជ្ញាសូមដាក់ជូននូវចម្លើយតបរួមនេះទៅនឹងចម្លើយនានា[2] ដែលបានដាក់ដោយ នួន ជា, អៀង ធីរិទ្ធ, អៀង សារី និង ខៀវ សំផន ("ចម្លើយតប") ក៏ដូចជា សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ[3] ដែលបានឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[4]។

២- ដោយសារមានការកម្រិតចំនួនទំព័រ គេមិនអាចឆ្លើយតបដោយឡែកៗ ទៅនឹងអំណះអំណាងទាំងអស់ ដែលបានលើកឡើងនៅក្នុងចម្លើយតបទាំងនោះបានទេ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានរក្សានូវគោលជំហររបស់ខ្លួន ដូចដែលមាននៅក្នុងសេចក្ដីសន្និដ្ឋានរបស់ កសព ហើយធ្វើការឆ្លើយតបបន្ថែមទៅនឹងបញ្ហាសំខាន់ៗទាំងនេះ ដែលបានលើកឡើងនៅក្នុងចម្លើយតបនានាគឺ៖ ទី១) ការជំទាស់នឹងការប្រើប្រាស់នូវគោលការណ៍អន្តរជាតិ ខណៈដែលចរិតលក្ខណៈនៃបទប្បញ្ញត្តិក្នុងស្រុកសន្មតថាមានន័យច្បាស់លាស់, ទី២) គោលការណ៍ប្រព័ន្ធច្បាប់ស៊ីវិលដែលពាក់ព័ន្ធ, ទី៣) អំណះអំណាងដែលថា យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបគាំទ្រដល់សិទ្ធិដែលគ្មានគុណវុឌ្ឍិ ដើម្បីកោះហៅសាក្សីសម្រាប់

---

[1] សេចក្ដីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា, E107/3, ថ្ងៃទី២ សីហា ២០១១ ។

[2] សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី, ថ្ងៃទី២១ កក្កដា ២០១១, E96/1, (**"ចម្លើយតបរបស់ នួន ជា"**) ។ ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ ទៅនឹង "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", E96/2, ថ្ងៃទី២២ កក្កដា ២០១១, (**"ចម្លើយតបរបស់ អៀង ធីរិទ្ធ"**) ។ ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, E96/3, ថ្ងៃទី២២ កក្កដា ២០១១, (**"ចម្លើយតបរបស់ អៀង សារី"**) ។ សេចក្ដីសង្កេតតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី, E96/4, ថ្ងៃទី២២ កក្កដា ២០១១, (**"ចម្លើយតប របស់ ខៀវ សំផន"**) ។

[3] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, E96/5, ថ្ងៃទី២២ កក្កដា ២០១១, (**"ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី"**) ។

[4] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៥ មិថុនា ២០១១, E96, ("សេចក្ដីសន្និដ្ឋានរបស់ កសព") ។

សវនាការ និងទី៤) អំណះអំណាងនានាពាក់ព័ន្ធនឹងកង្វះការទុកចិត្ត ឬកង្វះភាពត្រឹមត្រូវនៃភ័ស្តុតាងប្រភេទផ្សេងៗ។

## II. **ការឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តី**

### ក. ការប្រើប្រាស់នូវគោលការណ៍អន្តរជាតិនានា តាមមាត្រា៣៣ថ្មី នៃច្បាប់ អវតក

៣- ជាលក្ខណៈរួមនៃចម្លើយតបទាំងនោះ គឺអំណះអំណាងដែលថាគ្មានភាពស្រពិចស្រពិល នៅក្នុងនីតិវិធីបច្ចុប្បន្ននេះដែលយោងទៅតាមមេធាវីការពារក្តី គឺបានផ្តល់យ៉ាងមានប្រសិទ្ធភាពនូវសិទ្ធិមួយដែលគ្មានគុណវុឌ្ឍិ, មានលក្ខណៈដាច់ខាត ឬ "តាមបទបញ្ញា" ដើម្បីឲ្យជនជាប់ចោទធ្វើការសាកសួរដល់គ្រប់សាក្សីទាំងឡាយណាដែលកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន ត្រូវបានគេស្នើឡើងធ្វើជាភ័ស្តុតាង ព្រមទាំងដល់ជនទាំងឡាយណាដែលមិនមានកាលានុវត្តភាព ដើម្បីស្តាប់ចម្លើយនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[5]។ សហព្រះរាជអាជ្ញាក៏សូមជូនសេចក្តីសន្និដ្ឋានផងដែរថា មិនមែនគ្មានភាពរលូនរវាងនីតិវិធីទាំងនេះ និងបទដ្ឋានអន្តរជាតិនោះទេ ហើយថាភាពខុសគ្នាណាមួយក៏ដោយរវាងនីតិវិធី/បទដ្ឋានទាំងពីរនេះ គឺសុទ្ធតែដោយចេតនា។ នៅក្នុងកាលៈទេសៈទាំងនេះ មេធាវីការពារក្តីបានអះអាងថា គេពុំចាំបាច់អនុវត្តនូវវិធាននានាដែលបានបង្កើតឡើងនៅតាមកម្រិតអន្តរជាតិនោះទេ។ អៀង សារី បានបន្ថែមក្រោយមកទៀតថា នៅក្នុងហេតុការណ៍ណាក៏ដោយ សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញថាអង្គជំនុំជម្រះគួរតែប្រកាន់យកនូវវិធីសាស្ត្ររបស់តុលាការ *ចំពោះកិច្ច* (*ad hoc* tribunals) ជាជាងប្រកាន់យកនូវវិធីសាស្ត្រដែលមានលក្ខណៈរឹតត្បិតនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) ។ ចុងបញ្ចប់ អៀង ធិរិទ្ធ បានអះអាងថា សហព្រះរាជអាជ្ញាត្រូវបានរារាំងមិនឲ្យធ្វើការស្វែងរកនូវការទទួលយកកំណត់ហេតុស្តាប់ចម្លើយ(សាក្សី) ជាជំនួសវិញដោយការផ្តល់សក្ខីកម្មផ្ទាល់មាត់នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី។ អំណះអំណាងទាំងនេះ ត្រូវបានលើកឡើងដូចមាននៅខាងក្រោម៖

#### *ក(១). បញ្ហានានាស្តីពីការបកស្រាយមិនទាន់បានដោះស្រាយនៅក្នុងដំណើរការនីតិវិធីជាធរមាន*

[5] សហព្រះរាជអាជ្ញា បានកត់សម្គាល់ថា ខៀវ សំផន បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយនានា ជាជំនួសឲ្យ ការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់, ទោះបីជា នៅក្នុងកាលៈទេសៈដែលមានការកម្រិតនិងការលើកលែងយ៉ាងតឹងតែង ក៏ដោយ ។

៤- សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា បញ្ហានានាស្ដីពីការបកស្រាយបានកើតឡើងនៅក្រៅពីៈ ទី១) ភាពខុសគ្នានៃពាក្យពេចន៍នៅក្នុងអនុវិធាន៨៤.១ ក្នុងសំណៅជាបី(០៣)ភាសា គឺការមិនមានពាក្យថា "ដាច់ខាត" នៅក្នុងអត្ថបទជាភាសាខ្មែរ និងភាសាបារាំង និងការមិនមានពាក្យថា "ដែលប្រឆាំងនឹងគាត់" នៅក្នុងអត្ថបទជាភាសាបារាំង និងទី២) ភាពចាំបាច់ក្នុងការដោះស្រាយការខ្វែងគ្នាជាសក្ដានុពលរវាងសិទ្ធិក្នុងការសាកសួរសាក្សី និងកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានាឲ្យបានថាគេបានដំណើរការសវនាការបានយ៉ាងឆាប់រហ័ស និងបានរក្សានូវតុល្យភាពមួយរវាងភាគីនានា។

## *ក(១)(i). ពាក្យពេចន៍នៃបទប្បញ្ញត្តិ*

៥- ការមិនមានពាក្យថា "ដាច់ខាត" នៅក្នុងសំណៅជាភាសាខ្មែរ និងភាសាបារាំង នៃអនុវិធាន៨៤.១ គឺមានលក្ខណៈសំខាន់ណាស់។ ខ្លឹមសារនៃសារណាដែលបានដាក់ដោយជនជាប់ចោទនោះ គឺថាបទប្បញ្ញត្តិនេះពិតជាបានផ្ដល់យ៉ាងពិសេសនូវសិទ្ធិមួយដែលមានលក្ខណៈដាច់ខាត[6]។ នួន ជា បានអះអាងថាមាត្រា២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CCPC) បានដោះស្រាយនូវភាពស្រពិចស្រពិលនៅក្នុងអនុវិធាន៨៤.១ ព្រោះគេបានចែងថា សាក្សី "ត្រូវតែចូលខ្លួនក្នុងតុលាការ និងផ្ដល់សក្ខីកម្ម*ដោយផ្ទាល់មាត់* (*viva voce* testimony*)*"[7]។ យ៉ាងណាក៏ដោយ វាច្បាស់ខ្លាំងណាស់ដែលថានីតិវិធីក្នុងស្រុកជាធរមានបានបញ្ចូលនូវសិទ្ធិដែលមិនមាននគុណវុឌ្ឍិ ក្នុងការសាកសួរសាក្សីនានានៅពេលសវនាការ។ គម្រោងការមួយស្ដីពីការតាមឃ្លាំមើលសវនាការនាពេលថ្មីៗនេះ ដែលដំណើរការដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (Cambodian Center for Human Rights) បានរកឃើញថា "ក្នុងចំណោមសវនាការដែលបានតាមឃ្លាំមើលចំនួន៥៣២សវនាការ មានសាក្សីបានបង្ហាញខ្លួនតែក្នុង៨២សវនាការ"[8]។ របាយការណ៍នោះកត់សម្គាល់ថា ខណៈដែលជនជាប់ចោទមានសិទ្ធិក្នុងការកោះហៅនិងសាកសួរសាក្សីដែលគាំទ្រ និងសាក្សីដែលប្រឆាំងនឹងខ្លួន "សិទ្ធិនោះមិនត្រូវបានគេយល់ឃើញថាជាសិទ្ធិមួយដែលគ្មានគុណវុឌ្ឍិដើម្បីបង្ខំសាក្សីឲ្យមកចូលរួមទេ ឬដូចជាសិទ្ធិមួយក្នុងការកោះហៅសាក្សីនានាដែលមានចំនួនច្រើនមិនអាចកំណត់បាន"[9]។

[6] សេចក្ដីសន្និដ្ឋានរបស់ កសព, កថាខណ្ឌទី ៣-៤ ។

[7] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី ៣ ។

[8] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "សិទ្ធិនៅក្នុងការទទួលបាននូវការជំនុំជម្រះដ៏ត្រឹមត្រូវ នៅកម្ពុជា", ទំព័រទី ២៩ ។

[9] ដដែលដូចមុន, ទំព័រទី ២៨ ។

៦- សេចក្តីសន្និដ្ឋានខាងលើនេះ គឺត្រូវគ្នាទៅនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១ គឺដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព នៅពេលដែលអង្គជំនុំជម្រះបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៤ ដោយមិនបាច់តម្រូវឱ្យសាក្សីចូលមកបង្ហាញខ្លួនដើម្បីធ្វើការសាកសួរឡើយ។ ផ្ទុយពីសារណារបស់ អៀង សារី នៅក្នុងការបដិសេធមិនទទួលយកនូវកំណត់ហេតុនានារបស់សាក្សីចំនួនពីរ(០២)នាក់ដែលបានស្លាប់ គឺអង្គជំនុំជម្រះមិនបានពឹងផ្អែកតែទៅលើអង្គហេតុដែលជនជាប់ចោទមិនធ្លាប់បានធ្វើការសាកសួរពួកគេនោះទេ។ គេបានរើសយកវិធីសាស្ត្រមួយ ដែលត្រូវគ្នាទៅនឹងវិធានអន្តរជាតិដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព ដែលអនុលោមតាមនោះ អង្គហេតុដែលថាជនជាប់ចោទមិនមានលទ្ធភាពក្នុងការសាកសួរសាក្សី គឺជាជាការយល់ឃើញមួយដែលប្រឆាំងទៅនឹងការទទួលយកនូវកំណត់ហេតុទាំងនោះ (ដែលផ្ទុយទៅនឹងការរារាំងមិនឱ្យទទួលយក)[10]។ ក្រោយមក បទប្បញ្ញត្តិនានានៃវិធានផ្ទៃក្នុងដែលបានលើកឡើងដោយ អៀង សារី ក្នុងការគាំទ្រលើសិទ្ធិមួយដែលគ្មានគុណវុឌ្ឍិដើម្បីកោះហៅសាក្សីនានាទាក់ទងទៅនឹងបែបបទស្តាប់ចម្លើយសាក្សីទាំងឡាយណា ដែលគេបានកោះហៅឱ្យមកផ្តល់ភ័ស្តុតាងដោយផ្ទាល់មាត់ មិនមែនទាក់ទងទៅនឹងសិទ្ធិនៅក្នុងការសាកសួរសាក្សីនោះទេ[11]។

៧- ដោយមានកម្រិតស្មើគ្នា ពាក្យថា “ដែលប្រឆាំងនឹងគាត់” នៅក្នុងអនុវិធាន៨៤.១ គឺសំខាន់ ដោយហេតុថាវាជាការកម្រិតសិទ្ធិរបស់ជនជាប់ចោទក្នុងការសាកសួរសាក្សីនានានៅពេលសវនាការ។ នៅពេលដែលគេបកស្រាយតាមគោលការណ៍អន្តរជាតិដែលបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព ពាក្យពេចន៍ទាំងនេះមានន័យថា ជនជាប់ចោទមានសិទ្ធិក្នុងការសាកសួរសាក្សីនានាដែលត្រូវផ្តល់សក្ខីកម្មទៅលើអំពើ និងការប្រព្រឹត្តិរបស់ខ្លួន ឬមួយក៏ផ្តល់សក្ខីកម្មអំពីទិដ្ឋភាពស្នូលមួយផ្សេងទៀតនៃរឿងក្តីនោះ។ ចំពោះសាក្សីដែលនៅសល់ផ្សេងៗទៀត អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការទទួលយកកំណត់ហេតុ ជាជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់។ បើគេទទួលយកសារណារបស់មេធាវីការពារក្តី (ដែលថា ជនជាប់ចោទមានសិទ្ធិដាច់ខាត នៅក្នុងការសាកសួរសាក្សីទាំងអស់)នោះ ពាក្យថា “ដែលប្រឆាំងនឹងគាត់” នៅក្នុងសំណៅជាភាសាខ្មែរ និងភាសាអង់គ្លេសនៃអនុវិធាន ៨៤.១ ជាប្រសិទ្ធភាពនឹងមិនមានន័យអ្វីទាល់តែសោះ។

---

[10] សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភ័ស្តុតាង, E43/4, ថ្ងៃទី២៦ ឧសភា ២០០៩, កថាខណ្ឌទី ១៣-១៦ ។

[11] ចម្លើយតបរបស់ អៀង សារី, កថាខណ្ឌទី ៧-៩ ។

៨- នៅក្នុងការស្វែងរកការបង្ហាញឲ្យច្បាស់ពីការសន្មតលើភាពច្បាស់លាស់នៃល្បះ "ដែលប្រឆាំងនឹងគាត់)", នួន ជា បានស្នើជាដំណោះស្រាយមួយដែលមានលក្ខណៈភាសាសាស្ត្រសុទ្ធសាធ៖ គាត់អះអាងថា និយមន័យត្រូវយកតាមន័យធម្មតានៃពាក្យ "ប្រឆាំង"។ ប៉ុន្តែបន្ទាប់មក គាត់បានស្នើនិយមន័យមួយដែលទូលំទូលាយ៖ "<u>បុគ្គលណាម្នាក់</u>ដែលសក្ខីកម្មរបស់ខ្លួន<u>អាចបង្ហាញដល់ទិដ្ឋភាពនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា</u>"[12] (សង្កត់ន័យបន្ថែមដោយ<u>គូសបន្ទាត់ពីក្រោម</u>)។ មិនមានប្រភពច្បាប់ណាមួយត្រូវបានលើកឡើងគាំទ្រលើនិយមន័យនោះទេ ដែលការណ៍នេះបានបង្កើតឲ្យមានជាសំណួរច្រើនជាងចម្លើយ[13]។ អង្គហេតុពិតដែលថា "ប្រភពច្បាប់" ដែល នួន ជា បានពឹងផ្អែកនៅក្នុងការគាំទ្រលើអំណះអំណាង បកស្រាយតាមផ្លូវច្បាប់របស់ខ្លួន គឺជាវចនានុក្រម *ភាសាអង់គ្លេស* សាមញ្ញដែលបានបញ្ជាក់ទៅលើខ្លួនឯងពីភាពកម្រនៃប្រភពច្បាប់ក្នុងស្រុកអំពីប្រធានបទនេះ និងសេចក្តីត្រូវការក្នុងការសម្លឹងមើលទៅគោលការណ៍អន្តរជាតិដើម្បីធ្វើជាគោលការណ៍ណែនាំ។

៩- បើគេទទួលយកសារណានានារបស់មេធាវីការពារក្តី អង្គជំនុំជម្រះនឹងត្រូវមានកាតព្វកិច្ចធ្វើការកោះហៅសាក្សី*រូបណាមួយក៏ដោយ* ដែលកំណត់ហេតុរបស់ខ្លួនមានទំនោរទៅរកការគាំទ្រដល់ការលើកឡើងចោទប្រកាន់*ណាមួយ*ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាឧទាហរណ៍ អង្គហេតុពិតដែលថាកំណត់ហេតុរបស់សាក្សីម្នាក់ មិនទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទណាម្នាក់ក្នុងចំណោមជនជាប់ចោទទាំងអស់ ហើយភ័ស្តុតាងក៏ត្រូវគ្នានោះ មុខជានឹងមិនមានភាពទាក់ទងគ្នាទេ។ តាមវិធីសាស្ត្រនេះ អង្គជំនុំជម្រះសាលាដំបូងនឹងបាត់បង់នូវលទ្ធភាពនៅក្នុងការត្រួតពិនិត្យរយៈពេលនៃសវនាការ។ ដូចដែលបានបញ្ជាក់បង្ហាញនៅក្នុងផ្នែក ក(១)(ii) ខាងក្រោម ការណ៍នេះនឹង

---

[12] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី ៤.ខ ។

[13] ជាឧទាហរណ៍៖ អ្វីទៅជា **"ករណីរឿងចោទប្រកាន់"** នៅក្នុងដំណើរការនីតិវិធីដែលចៅក្រមជាអ្នកដឹកនាំធ្វើការសួរដេញដោល (inquisitorial proceeding)? នួន ជា បានស្នើនូវនិយមន័យមួយដែលមិនអាចធ្វើបាន៖ យោងទៅតាមគាត់ កាលណាអវត្តមាននៃអង្គហេតុដែលគ្មានការតវ៉ានោះ "ករណីរឿងចោទប្រកាន់" គឺថា "តាមនិយមន័យ ដោយជំទាស់ ដោយផ្ទុយ ដោយប្រឆាំង និង ជាសត្រូវ ទៅនឹងស្ថានភាពរបស់ជនចាប់ចោទ" ហើយគាត់ខកខានមិនបានពន្យល់នៅឡើយទេថា តើ "ស្ថានភាពរបស់ជនជាប់ចោទ" ត្រូវបានបង្កើតឡើងនៅក្នុងសវនាការមួយដែលមានជនជាប់ចោទច្រើនរូប យ៉ាងដូចម្តេចដែរ កាលណាជនជាប់ចោទម្នាក់ៗអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិននិយាយស្តី ។ និយមន័យរបស់គាត់បានបណ្តាលឲ្យអង្គជំនុំជម្រះទាយស្មានថាស្ថានភាពរបស់ជនជាប់ចោទអាចថាមានភាពផ្ទុយរបស់ខ្លួន ហើយបន្ទាប់មកស្រាវជ្រាវ រកផលពីនោះមក គឺជា "ករណីរឿងចោទប្រកាន់" ។ ការលើកស្នើឡើងនេះ គឺមិនមានមូលដ្ឋាននៅក្នុងយុត្តិសាស្ត្រជាតិ ឬ អន្តរជាតិ ទេ ។

បណ្ដាលឲ្យមានការបំពានទៅលើករណីយកិច្ចវិជ្ជមានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធានាថា គេត្រូវដំណើរការសវនាការនេះទៅតាមរបៀបមួយដែលឆាប់រហ័ស។

១០- អៀង សារី បានដាក់សារណាថា វិធានផ្ទៃក្នុងតំណាងឲ្យការបង្រួមចូលគ្នាមួយរវាងនីតិវិធីក្នុងស្រុក និងបទដ្ឋានអន្តរជាតិ ដូច្នេះហើយដំណោះស្រាយក្រោយៗទៀតដោយវិធានអន្តរជាតិ គឺមិនត្រូវបាន អនុញ្ញាតឡើយ[14]។ នៅក្នុងចម្លើយតប គឺគ្រប់គ្រាន់ណាស់ទៅហើយក្នុងការកត់សម្គាល់ថា ជាច្រើន លើកច្រើនសាមកហើយដែលអង្គជំនុំជម្រះនេះបានធ្វើការស្វែងរកការណែនាំជាអន្តរជាតិ ដើម្បីបក ស្រាយគោលការណ៍នានាដែលមាននៅក្នុងវិធានផ្ទៃក្នុង តាមកម្រិតពិស្ដារផ្សេងៗគ្នា[15]។ វាច្បាស់ លាស់ណាស់ដែលថា ខណៈដែលវិធានផ្ទៃក្នុងពិតជាមានចែងអំពីនីតិវិធីជាធរមាន នៅចំពោះមុខ អង្គជំនុំជម្រះនេះ វិធាននេះមិនបាន និងគ្រាន់តែមិនអាចដោះស្រាយបាននូវរាល់បញ្ហានីតិវិធីដែលអាច យល់បានយ៉ាងទូលំទូលាយទាំងអស់ដែលអាចនឹងកើតមានឡើងនៅក្នុងការអនុវត្តនោះ។ ចុងបញ្ចប់ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា អៀង សារី ខ្លួនឯង បានងាកទៅរកប្រភពអន្តរជាតិនានា ដើម្បីគាំទ្រដល់ការបកស្រាយរបស់ខ្លួនអំពីប្រយោគ "សាក្សីដាក់បន្ទុក"[16]។

*ក(១)(ii). សេចក្ដីត្រូវការដើម្បីសម្រុះសម្រួលពីសិទ្ធិក្នុងការកោះហៅសាក្សី នៅក្នុងបទប្បញ្ញត្តិផ្សេងៗទៀត*

១១- នីតិវិធីកម្ពុជាជាធរមាន តម្រូវឲ្យមានតុល្យភាពមួយអំពីសិទ្ធិនៅក្នុងការកោះហៅសាក្សី ដែលប្រកប ទៅដោយកាតព្វកិច្ចបញ្ចប់កិច្ចដំណើរការនីតិវិធីនៅក្នុងរយៈពេលមួយដ៏សមហេតុសមផល។ យ៉ាង

[14] ចម្លើយតបរបស់ អៀង សារី, កថាខណ្ឌទី ១៤ ។

[15] សូមមើល, ជាឧទាហរណ៍៖ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន, C20/5/17, ថ្ងៃទី១១ ឧសភា ២០០៩, កថាខណ្ឌទី ៥៥-៦០ ។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ នួន ជា, C11/54, ថ្ងៃទី២០ មីនា ២០០៨, កថាខណ្ឌទី ១៨-៣២ ។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជាចំពោះការចាត់តាំងអ្នកជំនាញ, D54/V/5, ថ្ងៃទី២២ តុលា ២០០៨, កថាខណ្ឌទី ១៨-២៧ ។ សាលដីការបស់អង្គបុរេជំនុំជម្រះលើភាពអាចទទួលយកបាននៃ "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ", D138/1/8, ថ្ងៃទី១៣ កក្កដា ២០០៩, កថាខណ្ឌទី ១៣-២៦ ។ សេចក្ដីសម្រេចលើសំណើសុំឲ្យពិនិត្យមើលឡើងវិញនូវសេចក្ដីសម្រេច ទាក់ទងនឹងសំណើសុំឲ្យមានសវនាការ ដើម្បីពិនិត្យបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អបជ ២៤ និង ២៥ , D164/3/5, ថ្ងៃទី២០ តុលា ២០០៩, កថាខណ្ឌទី ១៥-២៤ ។

[16] ចម្លើយតបរបស់ អៀង សារី, កថាខណ្ឌទី ៦ ។

ដូច្នេះក៏ដោយ ដូចដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញដូច្នោះដែរ គឺវាត្រូវទាក់ទងទៅនឹងការធ្វើឲ្យមានតុល្យភាពនេះដែលថានីតិវិធីក្នុងស្រុកមិនបានចែងពីគោលការណ៍ណែនាំឲ្យបានគ្រប់គ្រាន់នោះទេ[17]។

១២- កាតព្វកិច្ចក្នុងការបំពេញកិច្ចការឲ្យបានឆាប់រហ័ស គឺជាករណីយកិច្ចវិជ្ជមានមួយដែលបានឆ្លុះបញ្ចាំងនៅក្នុងបទប្បញ្ញត្តិមួយចំនួនដែលអាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះនេះ រួមទាំង មាត្រា៣៣ថ្មី នៃច្បាប់ អវតក (ដែលចែងថាសវនាការត្រូវតែត្រឹមត្រូវ *និង*ឆាប់រហ័ស), មាត្រា ១៤.៣.គ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងមាត្រា២៩ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អវតក។ ករណីយកិច្ចនេះធ្លាប់ត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ (អបជ) នៅក្នុងករណីរឿងនេះ[18] និងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ ០០១[19]។

១៣- ដូចដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ដូច្នោះដែរថា មាត្រា២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានកម្រិតដោយមាត្រា៣១៨ ដែលផ្តល់ឆន្ទានុសិទ្ធិដល់ប្រធានសវនាការ ដែលអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលដែលឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសម្តែងឲ្យឃើញការពិត[20] ។ ស្រដៀងគ្នានេះដែរ វិធាន៨៥ និង៨៧ នៃវិធានផ្ទៃក្នុង ទំនងជាផ្តល់នូវគុណវុឌ្ឍិដល់អនុវិធាន ៨៥.១ ។ អនុវិធាន៨៥.១ ចែងថា "ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំឲ្យទៅដល់ការស្វែងរកការពិត"។ អនុវិធាន ៨៧.៣ ចែងថា

---

[17] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌទី ១៦-១៨ ។

[18] សូមមើល, ជាឧទាហរណ៍៖ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងមិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល, C11/29, ថ្ងៃទី៤ កុម្ភៈ ២០០៨, កថាខណ្ឌទី ៨ ។ សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, C20/I/13, ថ្ងៃទី១ មេសា ២០០៨, កថាខណ្ឌទី ៥ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, C22/5/38, ថ្ងៃទី២៦ មិថុនា ២០០៩, កថាខណ្ឌទី ៤៣ ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ, D361/2/2, ថ្ងៃទី១២ ឧសភា ២០១០, កថាខណ្ឌទី ៥ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, D314/1/8, ថ្ងៃទី៨ មិថុនា ២០១០, កថាខណ្ឌទី ៧០ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/2/15, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ៨២ ។

[19] អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, E188, ថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌទី ៦៦៥ ។

[20] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌទី ១៣-១៥ ។

អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិនៅក្នុងការបដិសេធចំពោះ ពាក្យសុំឲ្យពិនិត្យភ័ស្តុតាង បើយល់ឃើញថា *លើសពីអ្វីៗទាំងអស់នោះ* វាជាការស្នើសុំជាន់គ្នា ឬជាការពន្យារដំណើរការនីតិវិធី។

១៤- វិធីសាស្ត្រដែលជនជាប់ចោទបានស្នើឡើង បានធ្វើឲ្យអង្គជំនុំជម្រះមិនអើពើនឹងកាតព្វកិច្ចរបស់ខ្លួន ក្នុងការដឹកនាំធ្វើសវនាការឲ្យមានប្រសិទ្ធភាព។ ពួកគេបានអះអាងថា បើសហព្រះរាជអាជ្ញាទទួចឲ្យមានសវនាការមួយដែលឆាប់រហ័សនោះ សហព្រះរាជអាជ្ញាមិនគួរនឹងផ្តួចផ្តើមឲ្យមានសំណុំរឿងព្រហ្មទណ្ឌមួយដ៏ធំបែបដូច្នេះឡើយ។ ការប្រៀបធៀបរបស់ នួន ជា អំពីករណីរឿងនេះ ទៅនឹង "Frankenstein" គឺជាការប្រមាថមើលងាយដល់ពួកជនរងគ្រោះ ដោយហេតុថាវាត្រូវបានដាក់ខុសកន្លែង[21]។ អ្វីដែលគាត់បានរៀបរាប់ពី "ការបង្កើត" របស់សហព្រះរាជអាជ្ញា គឺជាគំរូដ៏សមហេតុតំណាងឲ្យបណ្តុំឧក្រិដ្ឋកម្មយ៉ាងទូលំទូលាយមួយ ក្នុងចំណោមបណ្តុំឧក្រិដ្ឋកម្មយ៉ាងទូលំទូលាយទាំងឡាយ ដែលបានលើកឡើងចោទប្រកាន់ថាត្រូវបានប្រព្រឹត្តឡើងដើម្បីប្រឆាំងនឹងជាតិណាមួយនៅក្នុងប្រវត្តិសាស្ត្រទំនើប។ តាមរបៀបជាឧទាហរណ៍ជាក់ស្តែង សហចៅក្រមស៊ើបអង្កេត ("សចស") បានរកឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើត "មន្ទីរសន្តិសុខ ប្រហែល២០០កន្លែង និងកន្លែងសម្លាប់មនុស្សយ៉ាងច្រើនរាប់មិនអស់...នៅទូទាំងប្រទេសកម្ពុជា" ក្នុងអំឡុងពេលនោះ ដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ[22]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានមន្ទីរសន្តិសុខ១១កន្លែងដែលតំណាងឲ្យប្រមាណជា៥% នៃចំនួនគុកទាំងអស់ដែលបង្កើតបានជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់។

១៥- ចុងបញ្ចប់ មេធាវីការពារក្តីបានចាប់យកបញ្ហានេះជាមួយនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា ការអនុវត្តដ៏តឹងរ៉ឹងនូវអនុវិធាន ៨៤.១ នឹងមិនមានភាពរលូនទៅនឹងលក្ខខណ្ឌតម្រូវជាសារវន្តដើម្បីរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា ដែលត្រូវបានរកឃើញនៅក្នុងអនុវិធាន ២១.១.ក នោះទេ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ដើម្បីធ្វើការបកស្រាយអនុវិធាន ៨៤.១ ដូចដែលផ្តល់ឲ្យដល់ជនជាប់ចោទម្នាក់ៗនូវសិទ្ធិ ដែលគ្មានគុណវុឌ្ឍិក្នុងការសាកសួរសាក្សីទាំងឡាយណាដែលកំណត់ហេតុរបស់ខ្លួនត្រូវបានគេស្នើឡើងធ្វើជាភ័ស្តុតាងនោះ មុខជានឹងនាំឲ្យមានអតុល្យភាពមួយរវាងសិទ្ធិរបស់ភាគីនានាជាមិនខាន ពីព្រោះ៖ ទី១) សហព្រះរាជអាជ្ញាត្រូវទទួលបន្ទុកក្នុងការបង្ហាញ

[21] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី ៤.គ ។

[22] ដីកាដំណោះស្រាយ, D427, ថ្ងៃទី១៥ កញ្ញា ២០១០, កថាខណ្ឌទី ១៧៨ ។

សក្ខីកម្មពីពិរុទ្ធភាពរបស់ជនសង្ស័យឲ្យបានហួសពីវិមតិសង្ស័យ និង ទី២) នៅពេលជាមួយគ្នានោះ ពួកគាត់ត្រូវស្ថិតនៅក្រោមកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការគ្រប់គ្រងលើសវនាការឲ្យមានប្រសិទ្ធភាព ដែលការណ៍នេះមានន័យថា ដោយចៀសមិនរួច គឺចំនួនសាក្សីដែលពួកគាត់មានលទ្ធភាពអាចកោះហៅ នឹងត្រូវបានកម្រិតដោយអង្គជំនុំជម្រះ[23]។ នៅក្នុងកាលៈទេសៈទាំងនេះ ការអនុញ្ញាតឲ្យជនជាប់ចោទមានសិទ្ធិមួយដែលគ្មានលក្ខខណ្ឌក្នុងការកោះហៅសាក្សីចំនួនរាប់រយនាក់ ដែលសក្ខីកម្មរបស់ពួកគាត់មានការទាក់ទងគ្នាយ៉ាងទូលំទូលាយទៅនឹងមូលដ្ឋានឧក្រិដ្ឋកម្ម និងដែលស្របគ្នាទៅនឹងភស្តុតាងដទៃទៀត (រួមទាំង ភស្តុតាងដោយផ្ទាល់មាត់ផង ដែល*ទីដ*ត្រូវស្ថិតនៅក្រោមការសាកសួររបស់ភាគីនានានៅក្នុងតុលាការ) នោះគឺវាមិនមានភាពរលូនគ្នាទៅនឹងវិធាន ២១.១.ក ទេ។

*ក(២) អំពីការខ្វះចន្លោះ និងភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិនានា*

១៦- នួន ជា បានលើកសំអាងថា ប្រការដែលបទដ្ឋានអន្តរជាតិ "ជាក់លាក់កំរិតខ្ពស់" បានមានអត្ថិភាពនៅលើបញ្ហាមួយដែលច្បាប់កម្ពុជាមានភាពមិនសូវជាក់លាក់ដូច គឺវាមិនមែនជាមូលហេតុដើម្បីធ្វើការស្វែងរកការណែនាំនៅក្នុងបទដ្ឋានអន្តរជាតិនោះឡើយ[24]។ ការលើកឡើងដូចនេះគឺជាការធ្វើមិនដឹងមិនឮចំពោះប្រការដែលថានីតិវិធីជាធរមានរបស់កម្ពុជា មិនបាននិយាយអំពីបញ្ហាជាគន្លឹះនានាជាច្រើនដែលរួមមាន៖ អំពីការទទួលយកនូវចម្លើយសាក្សី។ អត្ថន័យនៃប្រយោគ "ផ្តល់ចម្លើយជាសាក្សីប្រឆាំងនឹងរូបគាត់" ហើយដូចដែលបានបង្ហាញជាសញ្ញាឲ្យឃើញខាងលើ អំពីវិធីដែលអង្គជំនុំជម្រះសាលាដំបូងគួរតែខំធ្វើឲ្យមានតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការកោះហៅសាក្សីនានា និងកាតព្វកិច្ចរបស់ខ្លួន ក្នុងការធ្វើការសន្និដ្ឋានបញ្ចប់ការជំនុំជម្រះក្តីឲ្យបាន ក្នុងពេលវេលាមួយដ៏សមស្រប។ និយាយទូលំទូលាយជាងនេះគឺ ការលើកឡើងនេះធ្វើមិនដឹងមិនឮចំពោះអង្គហេតុដ៏ជាក់ស្តែងដែលថា នីតិវិធីព្រហ្មទណ្ឌក្នុងស្រុករបស់កម្ពុជាមិនត្រូវបានធ្វើការអភិវឌ្ឍន៍សម្រាប់ករណីរឿងនានាតួយ៉ាងដូចជា ករណីរឿងចំពោះមុខនេះទេ៖ ដែលចោទប្រកាន់អំពីឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំ និងពឹងផ្អែកយ៉ាងខ្លាំងទៅលើច្បាប់អន្តរជាតិ។

[23] ការណ៍នេះគឺធ្លាប់បានលេចឡើងរួចហើយពីបញ្ជីឈ្មោះសាក្សីសាកល្បងរបស់អង្គជំនុំជម្រះ ដែលបានចែកចាយនៅពេលសវនាការបឋមនាពេលថ្មីៗនេះ ។

[24] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី៤(ឃ)។

១៧- គ្រាន់តែជាការមិនត្រឹមត្រូវផងដែរ ដែលពោលអះអាងថា បទដ្ឋាននានារបស់កម្ពុជាមានភាពតឹងតែង ជាងបទដ្ឋានទាំងឡាយដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ដែលអាស្រ័យហេតុនេះ គឺបានផ្តល់នូវការការពារមួយដែលមានកំរិតខ្ពស់ជាងមុន[25]។ ដូចដែលបានលើកឡើងបង្ហាញឱ្យឃើញច្បាស់ នៅក្នុងផ្នែក ក(១)ខាងលើ តុលាការនានារបស់កម្ពុជាមានឆន្ទានុសិទ្ធដែលលប់លើអ្វីៗទាំងអស់ក្នុងការដកចេញនូវភស្តុតាងដែលធ្វើឱ្យអូសបន្លាយពេលដល់ដំណើរការនីតិវិធី។ ចម្លើយសាក្សីត្រូវបានស្តាប់តិចតួចណាស់ មិនសូវញឹកញាប់ខ្លាំងដូចជាសាក្សីដែល នួន ជា បានស្នើឡើងនោះទេ។

១៨- មានសក្តានុពលដ៏សំខាន់ខ្លាំងណាស់ សម្រាប់ភាពមិនស៊ីសង្វាក់គ្នារវាងអនុវិធាន៨៤(១)នៃវិធានផ្ទៃក្នុង (បើសិនជាធ្វើការបកស្រាយទៅតាមរបៀបដែលជនជាប់ចោទបានស្នើ) និងបទដ្ឋានអន្តរជាតិ។ បទដ្ឋានទាំងនោះមិនទទួលស្គាល់ចំពោះសិទ្ធិក្នុងការសួរដេញដោលរាល់សាក្សីទាំងអស់ (របស់ភាគីបដិបក្ខ)នៅក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌទេ[26]។ ប៉ុន្តែបានដាក់កាតព្វកិច្ចមួយទៅលើអង្គជំនុំជម្រះ ដើម្បីឱ្យបើកធ្វើសវនាការជំនុំជម្រះក្តីឱ្យបានយ៉ាងឆាប់រហ័ស។ ផ្ទុយពីការលើកឡើងរបស់ អៀង សារី កាតព្វកិច្ចនេះ គឺជាគោលការណ៍ស្នូលមួយរបស់ច្បាប់អន្តរជាតិ។ មាត្រា១៤(៣)(គ)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ បានចែងនៅក្នុងផ្នែកដែលទាក់ទងថា៖ "ក្នុងការកំណត់សម្រេចអំពីបទចោទប្រកាន់ណាមួយចំពោះរូបគាត់ ជនគ្រប់រូបត្រូវមានសិទ្ធិក្នុងការទទួលបាននូវការធានាក្នុងកំរិតអប្បបរមា...(គ) ត្រូវបានទទួលការជំនុំជម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលា ដោយមិនត្រឹមត្រូវ"។ សេចក្តីអធិប្បាយផ្តល់មតិរបស់គណៈកម្មាធិការសិទ្ធិមនុស្សលើបញ្ញត្តិនេះ បានសង្កត់ធ្ងន់អំពីសារសំខាន់ ក្នុងការធានាថាជនជាប់ចោទត្រូវបានជំនុំជម្រះក្តី "ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន" ជាពិសេសបើសិនជាជននេះត្រូវឃាត់ខ្លួនបណ្តោះអាសន្ន[27]។ នៅក្នុងការធ្វើសេចក្តីអត្ថាធិប្បាយផ្តល់មតិលើបញ្ញត្តិណាមួយ ក្នុងក្របខណ្ឌដែលស្រដៀងគ្នានឹងមាត្រា៣៣ថ្មីនៃច្បាប់ អវតក អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានបញ្ជាក់ច្បាស់អំពីសារសំខាន់នៃសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលាដោយមិនត្រឹមត្រូវ និង

[25] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី៦។

[26] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអធិប្បាយផ្តល់មតិជាទូទៅលេខ ៣២៖ មាត្រា១៤ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាក្តីនានា ហើយនិងសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌, ចុះថ្ងៃទី២៣ សីហា២០០៧ , ឯកសារលេខ CCPR/C/GC/32, កថាខណ្ឌទី៣៩។

[27] ដូចគ្នានឹងខាងលើ កថាខណ្ឌទី៣៥ (លេខយោងជើងទំព័រត្រូវបានដកចេញ)។

ដាក់ភារកិច្ចដែលពាក់ព័ន្ធគ្នានេះដល់តុលាការ ដើម្បីឱ្យដំណើរការសវនាការឱ្យបានឆាប់រហ័សៈ "សិទ្ធិរបស់ជនជាប់ចោទមិនគ្រាន់តែត្រូវបានធានាឱ្យទទួលបាននូវការជំនុំជម្រះក្តី ដោយគ្មានការអូសបន្លាយពេលដោយមិនត្រឹមត្រូវប៉ុណ្ណោះទេ ក៏ប៉ុន្តែលក្ខន្តិកៈបានចែងមួយជំហានលើសពីនេះទៅទៀត។ មាត្រា៦៤(២)នៃលក្ខន្តិកៈបានដាក់កាតព្វកិច្ចអនុវត្តដល់តុលាការដើម្បីឱ្យបើកធ្វើសវនាការជំនុំជម្រះក្តី ដែលមិនគ្រាន់តែឱ្យបានត្រឹមត្រូវយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែសវនាការនេះត្រូវតែឱ្យបានឆាប់រហ័សផងដែរ"[28]។

១៩- បទដ្ឋានអន្តរជាតិនានាមានចែងអំពីការណែនាំដ៏មានសារសំខាន់ស្តីពីបញ្ហាដំណើរការនីតិវិធីដោយឆាប់រហ័ស។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ដែលជាតុលាការអន្តរជាតិដំបូងគេដែលមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់តាំងពីសម័យកាលតុលាការនានានៃទីក្រុងនូរ៉ាំប៊ឺហ្គមក ពីដើមដំបូងគេចូលចិត្តការផ្តល់សក្ខីកម្មផ្ទាល់មាត់របស់សាក្សីដោយផ្ទាល់នៅក្នុងពេលសវនាការ។ ជាលទ្ធផល "ការជំនុំជម្រះក្តីបានអភិវឌ្ឍន៍ដោយមានការប្រកែកតវ៉ាគ្នាមិនចេះចប់មិនចេះហើយរវាងភាគីនានា ដែលគោលដៅសំខាន់របស់ពួកគេ គឺដើម្បីឈ្នះនៅក្នុងការប្រយុទ្ធទាំងនេះ គឺមិនមែនដើម្បីជំរុញឱ្យដំណើរការនីតិវិធីបានឆាប់រហ័ស និងការសន្សំសំចៃថវិកាដល់តុលាការនោះឡើយ"[29]។ វិធីដំណើរការនេះត្រូវបានកែប្រែដោយវិធាន ៩២*ស្ទួន* ដែលបានអនុញ្ញាតឱ្យទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកជាជំនួសឱ្យការធ្វើសក្ខីកម្មដោយផ្ទាល់មាត់ ដរាបណាពួកគេមិនឈានទៅដល់ការផ្តល់សក្ខីកម្មអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ[30]។ មូលហេតុជាសំខាន់នៃការងាកទៅរកការទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរវិញនោះ គឺដើម្បី "ផ្តោតទៅលើ ការធ្វើសវនាការជំនុំជម្រះក្តីដែលមានលក្ខណៈខ្លីជាង និងចំណាយថវិការអស់តិចជាង" ដែលជាការកាត់បន្ថយការអូសបន្លាយពេលតិចជាងសម្រាប់ជនជាប់ចោទដែលកំពុងស្ថិតនៅក្នុងការឃាត់ខ្លួនបណ្តោះអាសន្ន និង

---

[28] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី I ដែលមានចំណងជើងថាៈ "សេចក្តីសម្រេចស្តីពីការដោះលែងឈ្មោះ Thomas Lubanga Dyilo", ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Thomas Lubango Dyilo, សំនុំរឿងលេខ ICC-01/04-01/06 OA 12, ចុះថ្ងៃទី២១ តុលា ២០០៨, កថាខណ្ឌទី១៥។

[29] Jerome de Hemptinne, ការបង្កើតអង្គជំនុំជម្រះស៊ើបសួរនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, ទំព័រ៤០៥។

[30] Patricia Wald, ដែលទាក់ទងនឹងសាក្សីនានានៅក្នុងការជំនុំជម្រះក្តីករណីរឿងឧក្រិដ្ឋកម្មសង្គ្រាមៈ មេរៀនពីតុលាការរបស់យូហ្គោស្លាវី, ទំព័រ២២៧។

ធ្វើឱ្យកាន់តែមានជំនឿទុកចិត្តថែមទៀតទៅលើសមត្ថភាពរបស់តុលាការ ក្នុងការធ្វើឱ្យការងាររបស់ខ្លួនបានចប់សព្វគ្រប់"[31]។ មានការពាក់ព័ន្ធដែលត្រូវធ្វើការកត់សំគាល់ផងដែរថា ការប្រើប្រាស់នូវចម្លើយរបស់សាក្សីជាលាយលក្ខណ៍អក្សរជាជំនួសឱ្យចម្លើយសាក្សីដោយផ្ទាល់មាត់ គឺត្រូវបានអនុញ្ញាតយ៉ាងទូលំទូលាយនៅក្នុងការដោះស្រាយវិវាទជាអន្តរជាតិ[32]។

២០- សេចក្តីត្រូវការចាំបាច់ឱ្យចាត់ចែងការជំនុំជម្រះក្តីឱ្យបានដំណើរការដោយឆាប់រហ័ស ក៏បានដឹកនាំទៅរកការកែទម្រង់ផ្សេងៗទៀតដែរនៅឯតុលាការ ICTY ដូចជាការដាក់តម្រូវឱ្យមានជាពេលវេលាកំណត់ទៅលើភាគីនានាសម្រាប់ការផ្តល់ភ័ស្តុតាង។ នៅក្នុងសៀវភៅក្បួនណែនាំសម្រាប់អនុវត្តន៍របស់តុលាការ ICTY ស្តីពីការអនុវត្តដែលត្រូវបានអភិវឌ្ឍន៍ បានចែងថា៖

*ដោយសារការយល់ឃើញអំពីបរិមាណដ៏ធំធេងនៃឯកសារនានាដែលត្រូវបង្ហាញជូន អំពីរយៈពេលនៃអំពើល្មើសព្រហ្មទណ្ឌនានាដែលត្រូវបានចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអំពីបញ្ហានានាស្តីពីការគ្រប់គ្រងសំណុំរឿងដែលមានជាប់មកជាមួយស្រាប់ ដែលលេចឡើងនៅក្នុងអង្គុងពេលដែលមានបញ្ហាក្តីក្នុងករណីរឿងព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសនៅក្នុងករណីដែលមានជនជាប់ចោទយ៉ាងច្រើន ការបង្ហាញភ័ស្តុតាងអាចត្រូវបានយល់ឃើញថាអាចបន្តទៅទៀតបានដោយគ្មានពេលវេលាកំណត់។ ហេតុដូចនេះ ការដាក់តម្រូវនូវពេលវេលាកំណត់ជារួមទាំងមូល គឺត្រូវបានយល់ឃើញថាជាវិធានការដ៏ចាំបាច់ និងដ៏មានប្រយោជន៍[33]។*

២១- ការអនុវត្តជាច្រើនប្រភេទនេះត្រូវបានអនុម័តយកដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿងលេខ០០១ ដែលក្នុងនោះពេលវេលាកំណត់ជាក់លាក់ត្រូវបានគេកំណត់សម្រាប់ការពិនិត្យសាក្សីនានារបស់ភាគីនីមួយៗ[34]។

[31] ដូចគ្នានឹងខាងលើ ទំព័រ២២៩-២៣០។

[32] John Wolf & Kelly Preteroti, ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ-គឺជាស្ពាននៃការអនុវត្តន៍នាំទៅរកការបែងចែកនៃវប្បធម៌, ទំព័រ ៨៥។

[33] សៀវភៅណែនាំអនុវត្តន៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ស្តីពីការអនុវត្តដែលត្រូវបានអភិវឌ្ឍន៍, ឆ្នាំ ២០០៩, ទំព័រ៧៨។

[34] ប្រតិចារិក, ឯកសារលេខE1/46.1,ចុះថ្ងៃទី៩ កក្កដា ២០០៩ , ទំព័រ៦២។

២២- ការលើកឡើងនូវទឡ្ហករណ៍របស់ នួន ជា ដែលថា ការយោងនៅក្នុងមាត្រា៣៣ថ្មីនៃច្បាប់ អវតក ទៅលើ “បទដ្ឋានអន្តរជាតិ” ត្រូវបានកំរិតឲ្យនៅត្រឹមជាគោលការណ៍នៃការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌មួយដែលមានវិសាលភាពដ៏តូចចង្អៀតនោះ ក៏ត្រូវតែបរាជ័យដែរ[35]។ នៅពេលដែលមានភាពច្បាស់លាស់ថាការធានាឲ្យមានការជំនុំជម្រះក្តី ដោយត្រឹមត្រូវយុត្តិធម៌មានសារសំខាន់ជាសារវ័ន្តនោះ តុលាការតែងតែពិនិត្យពិចារណាផងដែរ ទៅលើគោលការណ៍អន្តរជាតិផ្សេងៗទៀតដែលទាក់ទង ដែលរួមបញ្ចូលទាំងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាផង ក្នុងការធានាថាជនរងគ្រោះទាំងឡាយដោយអំពើបំពារបំពានសិទ្ធិដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា ICCPR ថា ត្រូវមានការដោះស្រាយសំណងជួសជុលតាមផ្លូវច្បាប់មួយដ៏មានប្រសិទ្ធភាព[36]។ ឧទាហរណ៍ដូចជា ដោយពិចារណាទៅលើផលប្រយោជន៍ដែលជាមូលដ្ឋានទ្រទ្រង់នូវ *គោលការណ៍មិនឲ្យមានការជំនុំជម្រះក្តីពីរដងចំពោះអង្គហេតុតែមួយ* នៅក្នុងច្បាប់អន្តរជាតិនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា៖ “[]ផលប្រយោជន៍ទាំងនេះ ត្រូវតែធ្វើការថ្លឹងថ្លែងជាមួយនឹងផលប្រយោជន៍របស់សហគមន៍អន្តរជាតិ និងរបស់ជនរងគ្រោះនានា ដើម្បីនឹងធានាថាជនទាំងឡាយដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋនានាក្រោមច្បាប់អន្តរជាតិត្រូវបានធ្វើការជំនុំជម្រះក្តីដោយត្រឹមត្រូវ។[លេខយោងជើងទំព័រត្រូវបានភ្លេច]”[37]។ ក្នុងការពិចារណាលើបទដ្ឋានអន្តរជាតិនានាដែលទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចូលរួមនៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យពិចារណាទៅលើលិខិតុបករណ៍នានាជាច្រើនដែលរួមទាំង សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌សំរាប់ជនរងគ្រោះ ដោយសារឧក្រិដ្ឋកម្ម និងការរំលោភអំណាច[38]។

២៣- ចុងបញ្ចប់ អៀង ធីរិទ្ធ បានពោលអះអាងថា ការអនុវត្តក្នុងការទទួលយកនូវចម្លើយសាក្សីនៅបណ្តាតុលាការ *ពិសេសនានា* គួរតែត្រូវបានធ្វើផ្សេងខុសពីគ្នា។ នេះគឺព្រោះថា នៅឯតុលាការទាំងនេះ មេធាវីការពារក្តីស្ថិតនៅក្នុងស្ថានភាពមួយដែលល្អប្រសើរជាងនេះ ដោយសារតែពួកគេត្រូវបានគេផ្តល់ឲ្យនូវ

---

[35] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌទី៧-៨។

[36] មាត្រា២(៣), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[37] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារលេខ D427/1/30, ចុះថ្ងៃទី១១ មេសា ២០១១, កថាខណ្ឌទី១៤៣។

[38] ដីកាសម្រេចស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារលេខC11/53, ចុះថ្ងៃ ទី២០ មីនា ២០០៨, កថាខណ្ឌទី៣០-៣៤។

"ចម្លើយសាក្សីពេញលេញ" នៅមុនពេលចាប់ផ្តើមសវនាការជំនុំជម្រះក្តី[39]។ ទឡ្ហីករណ៍នេះគឺមិនអាចទប់ទល់នឹងការពិនិត្យពិច័យដោយហ្មត់ចត់បានទេ។ តាមពិតទៅ មេធាវីការពារក្តីនៅ អវតក គឺស្ថិតនៅក្នុងស្ថានភាពដែលល្អប្រសើរយ៉ាងខ្លាំងជាងនេះទៅទៀត។ នៅតាមបណ្តាតុលាការ *ពិសេសនានា* មេធាវីការពារក្តីបានទទួលនូវចម្លើយសង្ខេបរបស់សាក្សីនានា ដែលត្រូវបានស្រង់យកដោយអ្នកស៊ើបអង្កេតទាំងឡាយដែលបម្រើការងារនៅក្រោមការត្រួតមើលពីលើរបស់រដ្ឋអាជ្ញា។ ក្នុងករណីភាគច្រើនបំផុត គឺចម្លើយទាំងនេះមិនមានអមដោយការថតសម្លេងនៃការធ្វើសម្ភាសន៍សាក្សីមកជាមួយផងទេ។ រដ្ឋអាជ្ញាទាំងឡាយនៃតុលាការ ICTY ចាំបាច់ត្រូវបញ្ចេញឲ្យដឹងអំពីចម្លើយទាំង លុះត្រាតែនៅពេលបន្ទាប់ពីមានការបញ្ជាក់ច្បាស់អំពីការចោទប្រកាន់ និងបន្ទាប់ពីការចូលបង្ហាញខ្លួនជាលើកដំបូងរបស់ជនជាប់ចោទតែប៉ុណ្ណោះ[40]។ នៅ អវតក ចម្លើយទាំងឡាយត្រូវបានស្រង់យកដោយបុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបំរើការងារក្រោមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត។ មេធាវីការពារក្តីមានសិទ្ធិអាចពិនិត្យមើលនូវចម្លើយទាំងនេះ និងអាចស្តាប់នូវការថតសម្លេងនៃការធ្វើសម្ភាសន៍សាក្សីទាំងស្រុងបាន នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវដោយអនុវិធាន៥៥(៥) នៃវិធានផ្ទៃ ក្នុងឲ្យ "ដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន ដោយអនាគតិ ទោះបីជាភ័ស្តុតាងដែលនឹងរកបាននោះជាភ័ស្តុតាងដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ" ដែលជាកាតព្វកិច្ចមួយដែលរដ្ឋអាជ្ញានៃតុលាការ ICTY មិនបានយកមកអនុវត្តនោះឡើយ [41]។

### *ក(៣) ថាតើវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) គួរតែត្រូវបានយកមកប្រើវិញ ឬយ៉ាងណា?*

២៤- ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់ អៀង សារី[42] នៅពេលដែលមិនអាចមានលទ្ធភាពផ្តល់ជូននូវការវិភាគដ៏ល្អិតល្អន់គ្មានសល់មួយបាន ស្តីពីភាពខុសគ្នារវាងក្របខណ្ឌនៃនីតិវិធីនានាដែលទាក់ទងរបស់តុលាការ *ពិសេសនានា* ហើយនិងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) នៅក្នុងការឆ្លើយតប

[39] ចម្លើយតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៣៨។

[40] អនុវិធាន៦៦(ក)(ii), វិធានស្តីពីនីតិវិធីនឹងភ័ស្តុតាងនៃតុលាការ ICTY ។

[41] មាត្រា១៦ នៃលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ទោះបីជា OTP មានកាតព្វកិច្ចត្រូវតែបង្ហាញឯកសារដោះបន្ទុកដល់មេធាវីការពារក្តីបន្ទាប់ពីការបញ្ជាក់ច្បាស់អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះក៏ដោយក៏ មិនមានការតម្រូវឲ្យស្វែងរកអំពីភាពលំអៀងនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរនោះទេ៖ វិធាន៦៨(i) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង។

[42] ចម្លើយតបរបស់ អៀង សារី , កថាខណ្ឌទី១៧-១៨។

នេះ សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហរដដែលថា នីតិវិធីរបស់តុលាការដែលលើកឡើងមុនគេ គឺត្រូវបានចូលចិត្តយកមកអនុវត្តជាង។ ដូចជា វិធានផ្ទៃក្នុង លក្ខន្តិកៈរបស់តុលាការ ICC បានទទួលស្គាល់ចំពោះសិទ្ធិរបស់ជនជាប់ចោទ ក្នុងការពិនិត្យមើលសាក្សីទាំងឡាយដែលប្រឆាំងនឹងខ្លួន[43]។ ក៏ប៉ុន្តែ ពួកអ្នកដែលធ្វើសេចក្តីព្រាងនៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICC (RoPE)បានចាត់វិធានការក្នុងការរឹតត្បិតបន្ថែមទៀតនៅក្នុងវិធាន៦៨, ការទទួលយកនូវចម្លើយសាក្សីនានាជាជំនួសឲ្យចម្លើយផ្ទាល់មាត់របស់សាក្សី ក្នុងករណីអយ្យការ និងជនជាប់ចោទ អាចមានលទ្ធភាពពិនិត្យសាក្សីបាននៅក្នុងពេលស្រង់យកចម្លើយ។ វិធីសាស្ត្រនេះមិនត្រូវបានយកមកប្រើនៅ អវតក ឬនៅតាមតុលាការ *ពិសេសនានា* នោះទេ។

២៥- លើសពីនេះទៅទៀត នៅពេលដែលករណីយុត្តិសាស្ត្ររបស់តុលាការ ICC មានកំរិតនោះ (តុលាការនេះមិនទាន់បានចេញសាលក្រមលើកដំបូងរបស់ខ្លួននៅឡើយ) សូម្បីតែនៅក្នុងដំណាក់កាលដូចនេះក្តី ក៏ខុសគ្នាឆ្ងាយណាស់ពីការជាក់ស្តែងថា តុលាការនេះនឹងអាននូវវិធាន៦៨ថា គឺជាការបង្កើតឡើងនូវវិធីតែមួយគត់សម្រាប់ការដាក់បញ្ចូលនូវចម្លើយរបស់សាក្សី។ ទោះបីជាសេចក្តីសម្រេចដែលលើកឡើងជាសំអាងដោយសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី(CPLC)[44] មិនបាននិយាយដោយចំៗទាក់ទងទៅនឹងចម្លើយសាក្សីក៏ដោយហាក់ដូចជាបើកចំហរលទ្ធភាពឲ្យវិធីសាស្ត្រដែលមានគោលបំណងជាក់លាក់ជាងនេះ *ក្នុងចំណោមគោលបំណងផ្សេងៗជាច្រើនទៀត* ផ្តោតទៅលើគោលការណ៍ស្តីពីការវាយតម្លៃដោយសេរីលើភ័ស្តុតាង[45]។ នៅក្នុងសេចក្តីសម្រេចមួយថ្មីជាងនេះ អង្គជំនុំជម្រះសាលាដំបូងមួយទៀតរបស់តុលាការ ICC បានទទួលយក *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែក* នូវរាល់ចម្លើយសាក្សីទាំងអស់ ដោយធ្វើការកត់សំគាល់ថា ជនជាប់ចោទនឹងត្រូវបានផ្តល់ឱកាសឲ្យអាចពិនិត្យសាក្សីដែលប្រឆាំងនឹងខ្លួនបាន។ ភាគច្រើននៅក្នុងអង្គជំនុំជម្រះនេះបានកត់សំគាល់ថា "លក្ខន្តិកៈរបស់តុលាការ[ICC] គ្រាន់តែគ្រោងទុកជាមុនអំពីការសន្មតមួយដែលគាំទ្រដល់ការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ប៉ុន្តែមិនមែនសុទ្ធតែការ(ផ្តល់សក្ខីកម្ម)ដោយផ្ទាល់មាត់ទូទៅទាំង

---

[43] មាត្រា៦៧.១(ង) លក្ខន្តិកៈរបស់តុលាការ ICC។

[44] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌទី២២-២៤។

[45] ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃឯកសារចំនួនបួន, ស្ថានការណ៍នៅក្នុងសាធារណរដ្ឋកុងហ្គោ, ករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo, ឯកសារលេខ ICC-01/04-01/06 OA, ចុះថ្ងៃទី ១៣ មិថុនា ២០០៨, ទំព័រ២៤។

អស់នៅក្នុងនីតិវិធីទាំងមូលនោះទេ”[46]។ មានអត្ថបទមួយថ្មីនេះ បានឱ្យដឹងថា ដំណោះស្រាយរបស់តុលាការ ICC “ទំនងជាមាននិន្នាការចង់ធ្វើឱ្យស្រដៀងគ្នាទៅនឹងនីតិវិធីដែលបានអនុម័តយកដោយតុលាការ*ពិសេសទាន់*ដែរ ដោយមានទំនោរប្រុងនឹងយល់ព្រមទទួលយកចម្លើយសាក្សីជាលាយលក្សណ៍អក្សរដែលអនុញ្ញាតឱ្យភាគីម្ខាងទៀតសួរដេញដោលសាក្សីតែនៅពេលណា ដែលភ័ស្តុតាងហាក់ដូចជាមានភាពសំខាន់បំផុតតែប៉ុណ្ណោះ[47]។ អ្នកនិពន្ធបានជជែកតវ៉ាថា តុលាការ ICC គួរតែអនុម័តនូវវិធីសាស្ត្រដែលបានប្រកាន់យកដោយតុលាការ ICTY ដែលនៅក្រោមវិធាន៩២*ស្ទួន* ហើយអនុញ្ញាតឱ្យទទួលយកនូវចម្លើយសាក្សីនានាជាលាយលក្សណ៍អក្សរ ជាជំនួសឱ្យចម្លើយដោយផ្ទាល់មាត់របស់សាក្សី បើសិនជាភ័ស្តុតាងមិនទាក់ទងទៅនឹងអំពើ ឬការប្រព្រឹត្តិនានារបស់ជនជាប់ចោទ ឬទៅនឹងធាតុផ្សំដ៏សំខាន់បំផុតណាមួយនៃករណីរឿងក្តី[48]។

*២៦-* នៅក្នុងសារណានានារបស់ ខៀវ សំផន[49] ស្តីពីភាពអាចអនុវត្តបាននៃវិធានរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) គឺមិនធ្វើឱ្យខូចដល់យុត្តិសាស្ត្រអន្តរជាតិដែលបានលើកឡើងជាសំអាងនៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះឡើយ តាមពិតទៅសារណាទាំងនោះគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ កសព ទៅវិញទេ។ វិធាន១៥៥ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ STL បានអនុម័តការបែងចែកដាច់ដោយឡែកពីគ្នារវាងភ័ស្តុតាងដែលសំដៅទៅរកអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ហើយនឹងភ័ស្តុតាងដទៃទៀត។ បើសិនជាភាគីនានាមានឱកាសអាចពិនិត្យសាក្សីណាមួយនៅពេលដែលគេកំពុងត្រូវបានស្រង់យកចម្លើយនោះ គឺគ្រាន់តែជាកត្តាមួយដែលគាំទ្រចំពោះការទទួលយកចម្លើយជាលាយលក្សណ៍អក្សរ ដែលជំនួសឱ្យចម្លើយដោយផ្ទាល់មាត់របស់សាក្សីតែប៉ុណ្ណោះ។

---

[46] សេចក្តីសម្រេចស្តីពីការទទួលយកជាភ័ស្តុតាងនូវឯកសារនានាដែលមាននៅក្នុងបញ្ជីភ័ស្តុតាងរបស់អយ្យការ, ស្ថានការណ៍នៅក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅក្នុងករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Jean-Pierre Bemba Gombo, សំណុំរឿងលេខ ICC-01/05-01/08, ចុះថ្ងៃទី១៩ វិច្ឆិកា ២០១០, កថាខណ្ឌទី១៤ និងទី២០ (លេខយោងជើងទំព័រត្រូវបានដកចេញ)។ ដោយទទួលស្គាល់នូវសិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យសាក្សីដែលប្រឆាំងនឹងខ្លួន អង្គជំនុំជម្រះបានយោងទៅលើយុត្តិសាស្ត្ររបស់ ECtHR ដែលដូចបានបញ្ជាក់នៅក្នុងផ្នែកគ, គឺមិនទទួលស្គាល់នូវសិទ្ធិដែលមិនមានគុណវុឌ្ឍិណាមួយដើម្បីតទល់នឹងសាក្សីនានានៅក្នុងពេលសវនាការនោះឡើយ៖ កថាខណ្ឌទី២០។

[47] Michelle Caianiello, សេចក្តីសម្រេចលើកដំបូងបង្អស់ស្តីពីការទទួលយកភ័ស្តុតាង នៅក្នុងសវនាការនៃតុលាការ ICC- ការលាយបញ្ចូលគ្នាមួយនៃគំរូរបស់ប្រព័ន្ធនីតិវិធីចោទប្រកាន់តាមបែប អង់គ្លេសអាមេរិកាំង និងប្រព័ន្ធតាមបែបបារាំងដែលចៅក្រមជាអ្នកដឹកនាំការជជីកសួរនៅក្នុងសវនាការ?, ទំព័រ ៤០០។

[48] ដូចគ្នានឹងខាងលើ , សេចក្តីសន្និដ្ឋាន។

[49] ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌទី២៦-២៨។

### *ក(៤) សហព្រះរាជអាជ្ញាមិនត្រូវបានរារាំងការប្រែក្រឡាស់ ពីការស្វែងរកការទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរនោះឡើយ*

២៧- អៀង ធិរិទ្ធ បានអះអាងថា សហព្រះរាជអាជ្ញាត្រូវបានរារាំងមិនឱ្យប្រែក្រឡាស់ ដើម្បីពឹងផ្អែកទៅលើការស្វែងរកការទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរវិញនោះទេ ពីព្រោះនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាមិនបានផ្តល់នូវសេចក្តីជូនដំណឹងអំពីចេតនារបស់ខ្លួន ដែលចង់ធ្វើសំណើដូចខាងលើនេះនៅពេលសវនាការនោះឡើយ[50]។ សហព្រះរាជអាជ្ញាបានកត់សំគាល់ឃើញថា ទស្សនទាននៃការរារាំងការប្រែក្រឡាស់ នៅក្នុងច្បាប់របស់កម្ពុជាគឺមិនដែលស្គាល់ឡើយ ឬទូលំទូលាយជាងនេះ គឺនៅក្នុងច្បាប់ទម្លាប់នៃប្រព័ន្ធច្បាប់ស៊ីវិល[51]។ ក៏ប៉ុន្តែ សូម្បីតែបើសិនជាត្រូវបានពិចារណាដោយផ្អែកលើមូលដ្ឋាននៃការពិចារណា ទៅតាមភាពអាចទទួលយកបានតាមសម្បជញ្ញៈដែលបង្កើតជាមូលដ្ឋានទ្រទ្រង់ដល់ទស្សនទាននៃការរារាំងការប្រែក្រឡាស់ ដែលប្រកបដោយសមធម៌នៅក្នុងប្រព័ន្ធច្បាប់Common Law[52] នោះទឡ្ហីករណ៍របស់ អៀង ធិរិទ្ធ គឺត្រូវបរាជ័យ។ គេបានស្នើឱ្យអង្គជំនុំជម្រះទទួលយល់ព្រមចំពោះការប្រឌិតដែលភាគីនានាមិនបានដឹងថាចម្លើយរបស់សាក្សីដែលបានផ្តល់ទៅឱ្យសហចៅក្រមស៊ើបអង្កេតអាចនឹងត្រូវបានស្នើសុំឱ្យចាត់ទុកជាភ័ស្តុតាង នៅក្នុងពេលសវនាការ ដើម្បីជំនួសឱ្យចម្លើយដោយផ្ទាល់មាត់របស់សាក្សី។ ដូចដែលបានធ្វើការកត់សំគាល់នៅក្នុងផ្នែក ខ ការប្រើប្រាស់នូវភ័ស្តុតាងជាលាយលក្ខណ៍អក្សរនៅក្នុងពេលសវនាការ គឺជានីតិវិធីយ៉ាងល្អមួយដែលត្រូវបានបង្កើតឡើងនៅក្នុងបណ្តាប្រទេសដែលប្រើប្រាស់នូវកិច្ចស៊ើបសួរ របស់តុលាការ។ ការពិនិត្យឡើងវិញជាមូលដ្ឋានមួយអំពីនីតិវិធីរបស់ប្រព័ន្ធច្បាប់ស៊ីវិល និងអំពីការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១ នឹងធ្វើឱ្យបានឱ្យមេធាវីរបស់ អៀង ធីរិទ្ធ បានជ្រាបអំពីស្ថានភាពនេះ[53]។ អាស្រ័យហេតុនេះ ការលើកឡើងនូវទឡ្ហីករណ៍អំពីទស្សនទាននេះ គឺគ្មានអង្គសេចក្តីនោះឡើយ។

---

[50] ចម្លើយតបរបស់ អៀង ធិរិទ្ធ, កថាខណ្ឌទី១២។

[51] អៀង ធីរិទ្ធ ខកខានមិនបានលើកសំអាងទៅលើបញ្ញត្តិណាមួយនៃច្បាប់កម្ពុជា ឬវិធាននៃផ្ទៃក្នុង ឬករណីយុត្តិសាស្ត្រណាមួយដើម្បីនឹងជួយគាំទ្រដល់ពាក្យសុំស្តីពីគោលការណ៍ការរាំងការប្រែក្រឡាស់(Estoppel)នៅចំពោះមុខតុលាការនេះ។

[52] Adam Kramer, អំពីគោលការណ៍ស្តីពីការរារាំងការប្រែក្រឡាស់ (Estoppel)ដែលមានច្រើន, ទំព័រ១៧។

[53] ឧទាហរណ៍ដូចជា អនុវិធាន៨៧.១ នៃវិធាននៃផ្ទៃក្នុងចែងថារាល់ភ័ស្តុតាងទាំងអស់អាចទទួលយកបាន និងអនុវិធាន៨៧.៣ ចែងថា អង្គជំនុំជម្រះ "ធ្វើសេចក្តីសម្រេចរបស់ខ្លួនដោយផ្អែកលើមូលដ្ឋាននៃភ័ស្តុតាងដែលបានមកពីសំណុំរឿង"។

## ខ. គោលការណ៍ច្បាប់ស៊ីវិល

២៨- នៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព សហព្រះរាជអាជ្ញាបានអះអាងថា ដើម្បីអនុវត្តនូវធានានុសិទ្ធិរបស់ខ្លួននៅក្នុងការកោះហៅសាក្សី អង្គជំនុំជម្រះគួរគិតគូរអំពីលក្ខណៈនៃនីតិវិធីច្បាប់ស៊ីវិល និងពិនិត្យ និងថ្លឹងថ្លែងឲ្យបានជាក់លាក់អ្វីដែលមានចែងនៅក្នុងនោះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថានៅពេលបានសាកល្បងក្នុងន័យប្រៀបធៀបចំពោះការពិចារណាទាំងអស់នោះ ការសន្និដ្ឋានរបស់ជនជាប់ចោទដែលថា នីតិវិធីរបស់កម្ពុជាអនុញ្ញាតផ្តល់សិទ្ធិដាច់ខាតដើម្បីពិនិត្យសាក្សីទាំងអស់ គឺមិនមានទេ។ កិច្ចស៊ើបសួរមិនលំអៀងមួយរួមបង្កើតបាននូវគោលការណ៍ដ៏សំខាន់មួយនៃនីតិវិធីនៃច្បាប់ស៊ីវិល និងការបែងចែកជាគន្លឹះមួយរវាងគំរូនៃនីតិវិធីច្បាប់ស៊ីវិល និងអង់គ្លោសាក់សុង។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជាប្រព័ន្ធច្បាប់អនុវត្តនៅកម្ពុជា គេដាក់សារសំខាន់តិចតួចប៉ុណ្ណោះទៅលើការសាកល្បងនៃភ័ស្តុតាងនៅពេលសវនាការ ដោយសារសវនាការជំនុំជម្រះក្តីដោយចៅក្រម ត្រូវបានបង្កប់យ៉ាងស៊ីជម្រៅនៅក្នុងកិច្ចដំណើរការស៊ើបសួរ”[54]។

២៩- ឯករាជភាព និងភាពមិនលំអៀងរបស់អ្នកស៊ើបអង្កេតតុលាការ ផ្តល់ជូននូវកិច្ចការពារដ៏សំខាន់ចំពោះសិទ្ធិរបស់ជនណាម្នាក់ដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ភ័ស្តុតាងត្រូវបានពិនិត្យ និងដាក់ក្នុងសំណុំរឿងដោយចៅក្រមដែលអ្នកស្រាវជ្រាវរកការពិត មិនមែនដោយភាគីណាមួយដែលអាចជាអ្នកដែលមានផលប្រយោជន៍ពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធីទេ[55]។ ជាលទ្ធផល កំណត់ហេតុសាក្សីនានាដែលបានដាក់ក្នុងសំណុំរឿង អាចត្រូវបានទទួលយកដោយពុំចាំបាច់ត្រូវកោះហៅសាក្សីមកផ្តល់ភ័ស្តុតាងនៅពេលសវនាការជំនុំជម្រះទេ។ នៅក្នុងការសិក្សាដ៏លម្អិតទៅលើសវនាការជំនុំជម្រះក្តីព្រហ្មទណ្ឌចំនួនប្រាំនៅប្រទេសបារាំង អ្នកនិពន្ធមួយរូបបានសង្កេតលើទ្រង់ទ្រាយសំខាន់ៗដូចតទៅ: ភ័ស្តុតាងប្រឆាំងនឹងចុងចោទនឹងត្រូវបានគេរកឃើញនៅក្នុងសំណុំឯកសារ មិនមែននៅក្នុងសក្ខីកម្ម និងវត្ថុតាងផ្សេងៗនៅពេលសវនាការជំនុំជម្រះក្តីទេ។ ក្នុងឧទាហរណ៍នៃសំណុំរឿងនេះ កំណត់ហេតុរបស់បុគ្គលចំនួន១៧នាក់ ក្រៅពីកំណត់ហេតុរបស់ចុងចោទ ត្រូវបានបញ្ចូលទៅក្នុងសំណុំឯកសារ

---

[54] Francis Pakes, យុត្តិធម៌ព្រហ្មទណ្ឌបែបប្រៀបធៀប, ទំព័រ៧៤ ។

[55] Jermone de Hemptinne, ការបង្កើតអង្គចៅក្រមស៊ើបអង្កេតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ, ទំព័រទី៤០៧ ។

ប៉ុន្តែមានតែមនុស្សម្នាក់ប៉ុណ្ណោះក្នុងចំណោមបុគ្គលទាំងអស់ត្រូវបានបង្ហាញខ្លួន នៅពេលសវនាការជំនុំជម្រះក្តី និងដោយសារតែគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងខូចខាតផ្សេងៗ”[56]។

៣០- ប្រព័ន្ធច្បាប់ស៊ីវិល បានអភិវឌ្ឍន៍នូវកិច្ចការពារផ្នែកនីតិវិធី ដើម្បីផ្តល់នូវការធានារ៉ាប់រងចំពោះការជំនុំជម្រះក្តីត្រឹមត្រូវយុត្តិធម៌។ ប្រព័ន្ធនេះរួមបញ្ចូលទាំងសិទ្ធិពិនិត្យមើលសំណុំឯកសារស៊ើបអង្កេតសម្រាប់ទាំងជនជាប់ចោទ និងមេធាវីការពារក្តីជនជាប់ចោទ[57]។ ប៉ុន្តែ ដូចបានកត់សំគាល់នៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព មេធាវីការពារក្តីមិនមានសេរីភាពដែលគ្មានកម្រិតព្រំដែននោះទេ នៅក្នុងការសួរសាក្សីរបស់ភាគីបដិបក្ខ[58]។ ជាការបន្ថែម ដោយហេតុគេមានប្រភពអំណាចតុលាការជាអ្នកមើលការខុសត្រូវទាំងនៅក្នុងដំណាក់កាលស៊ើបសួរ និងទាំងដំណាក់កាលជម្រះក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីតម្រូវការចាំបាច់នៃការមិនគោរពចំពោះព័ត៌មានដែលប្រមូលបាន នៅមុនពេលសវនាការជំនុំជម្រះត្រូវបានកាត់បន្ថយយ៉ាងច្រើន[59]។ កត្តាទាំងនេះគួរតែជាការជូនដំណឹងសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះ អំពីភាពចាំបាច់ ក្នុងការកោះហៅសាក្សីនៅពេលសវនាការជំនុំជម្រះក្តី។

## គ. យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប

៣១- សេចក្តីសន្និដ្ឋានរបស់ កសព បានលើកយោងករណីមួយចំនួនដែលតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប (ECtHR) បានបកស្រាយមាត្រា៦ នៃអនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលមិនបានផ្តល់ឲ្យជនជាប់ចោទនូវសិទ្ធិដែលគ្មានគុណវុឌ្ឍិ ដើម្បីកោះហៅសាក្សី និងសួរដេញដោលសាក្សី។ អៀង ធីរិទ្ធ បានយោងទៅលើលទ្ធផលនៃករណីទាំងអស់នោះដោយបានធ្វើការបង្ហាញឲ្យឃើញថា ការទទួលយកនូវកំណត់ហេតុជាលាយល័ក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ មិនស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ទេ[60]។

៣២- សេចក្តីយោងដែលបានធ្វើឡើងដោយ អៀង ធីរិទ្ធ មិនធ្វើទៅតាមករណីរបស់ ECtHR ទេ។ សាលក្រមបង្ហាញឲ្យឃើញថា តុលាការ ECtHR បានអនុវត្តការសាកល្បងមួយដែលអនុញ្ញាតឲ្យមានការ

[56] Bron McKillop, ការអាន និងការស្តាប់នៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសបារាំង: ករណីរឿងក្តីចំនួនប្រាំនៅក្នុងតុលាការកែប្រែ; យុត្តិធម៌ព្រហ្មទណ្ឌប្រទេសបារាំង, កថាខ័ណ្ឌទី៧៧៤ ។

[57] James G. Apple & Robert P. Deyling, បឋមភាពមួយស្តីពីប្រព័ន្ធច្បាប់ស៊ីវិល, ទំព័រទី២៨ ។

[58] Merryman, ជំពូក XVII នៃនីតិវិធីព្រហ្មទណ្ឌ, ប្រពៃណីនៃច្បាប់ស៊ីវិល, កថាខ័ណ្ឌទី១២៩ ។

[59] Francis Pakes, យុត្តិធម៌ព្រហ្មទណ្ឌបែបប្រៀបធៀប, ទំព័រ៨១ ។

[60] ចម្លើយតបរបស់ អៀង ធីរិទ្ធ, កថាខ័ណ្ឌទី២៤-៣៧; សូមអានផងដែរ ចម្លើយតបរបស់ អៀង សារី, កថាខ័ណ្ឌទី១៦ ។

ទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរជំនួសឱ្យភ័ស្តុតាងផ្ទាល់មាត់ ដោយត្រូវមានលក្ខខណ្ឌផ្សេងៗ។ ជាការសំខាន់ ការសាកល្បងរបស់ ECtHR អនុញ្ញាតឱ្យមានការប្រើប្រាស់នូវកំណត់ហេតុដោយពុំចាំបាច់មានសក្ខីកម្មផ្ទាល់មាត់ ប្រសិនបើ: i) ជនជាប់ចោទមានឱកាសគ្រប់គ្រាន់ដើម្បីតវ៉ាចំពោះភ័ស្តុតាងដែលប្រឆាំងនឹងរូបគាត់ និង ii) កំណត់ហេតុមិនត្រូវបានគេពឹងផ្អែក "តែមួយគត់ ឬសម្រាប់កម្រិតនៃការសម្រេច" ដើម្បីធ្វើជាភ័ស្តុតាងសម្រាប់ការកាត់ឱ្យជាប់ទោស[61]។ ថ្វីបើសារសំខាន់ដែល អៀង ធីរិទ្ធ បានស្វែងរកនោះ គឺដើម្បីផ្អែកលើលទ្ធផលនៃករណីរបស់តុលាការ ECtHR ដែលផ្ទុយនឹងគោលការណ៍ច្បាប់ដែលបានពិភាក្សានៅក្នុងនោះក៏ដោយ ក៏ករណីទាំងនោះគ្រាន់តែបង្ហាញពីការអនុវត្តការសាកល្បងខាងលើតែប៉ុណ្ណោះ។

៣៣- *នៅក្នុងករណី Unterpinger ទល់នឹង ប្រទេសអូទ្រីស, Saidi ទល់នឹង ប្រទេសបារាំង, Luca ទល់នឹង ប្រទេសអ៊ីតាលី, Delta ទល់នឹង ប្រទេសបារាំង, និង Van Mechelen និងអ្នកដទៃទៀត ទល់នឹង ប្រទេសហូឡង់,* តុលាការ ECtHR បានរកឃើញអំពីការរំលោភមាត្រា៦ ដោយសារតុលាការជំនុំជម្រះបានពឹងផ្អែកទៅលើកំណត់ហេតុជាលាយល័ក្ខណ៍អក្សរតែមួយគត់ ឬសម្រាប់ជាកម្រិតនៃការសម្រេច" ដើម្បីធ្វើជាភ័ស្តុតាងសម្រាប់ការកាត់ឱ្យជាប់ទោស[62] ។ ជាឧទាហរណ៍ ក្នុងករណី *Delta ទល់នឹង ប្រទេសបារាំង,* កំណត់ហេតុសាក្សីដែលពឹងផ្អែកដោយតុលាការជំនុំជម្រះ គឺជាភ័ស្តុតាងតែមួយគត់នៅក្នុងសំណុំរឿង ។ ស្រដៀងគ្នានេះ ដូចបានបង្ហាញយ៉ាងត្រឹមត្រូវដោយអៀង ធីរិទ្ធ ដែរ តុលាការ ECtHR បានរកឃើញថាមានការរំលោភក្នុងករណី*Unterpinger ទល់នឹង ប្រទេសអូទ្រីស* ដោយសារកំណត់ហេតុសាក្សីទាំងនោះ បង្កើតបានជាទម្រង់នៃភ័ស្តុតាងដ៏សំខាន់ដែលគេបានពឹងផ្អែកសម្រាប់ការកាត់ឱ្យជាប់ចោទ។ ភាពផ្ទុយគ្នាខុសស្រឡះពីអង្គហេតុនៃករណីទាំងនេះ គឺសហព្រះរាជអាជ្ញា មិនមែនស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើកំណត់ជាលាយល័ក្ខណ៍អក្សររបស់សាក្សី

[61] Unterpinger ទល់នឹង ប្រទេសអូទ្រីស, ២៤ វិច្ឆិកា ១៩៨៦, ពាក្យសុំលេខ 9120/80 (‘**Unterpertinger**’), កថាខ័ណ្ឌទី៣១ ។ Windisch ទល់នឹង ប្រទេសអូទ្រីស, ២៧ កញ្ញា ១៩៩០, ពាក្យសុំលេខ 1249/86, កថាខ័ណ្ឌទី២៦ និង ៣១ ។ Delta ទល់នឹង ប្រទេសបារាំង, ១៩ ធ្នូ ១៩៩០, ពាក្យសុំលេខ 11444/85 (‘**Delta**’), កថាខ័ណ្ឌទី៣៦-៣៧ ។ Asch ទល់នឹង ប្រទេសអូទ្រីស, ២៦ មេសា ១៩៩១, ពាក្យសុំលេខ 12398/86, កថាខ័ណ្ឌទី២៥, ២៧ និង ៣០ ។ Saidi ទល់នឹង ប្រទេសបារាំង, ២០ កញ្ញា ១៩៩៣, ពាក្យសុំលេខ 14647/89 (‘**Saidi**’), កថាខ័ណ្ឌទី៤៣ ។ Van Mechelen និងអ្នកដទៃទៀត ទល់នឹង ប្រទេសហូឡង់, ១៨ មីនា ១៩៩៧, សំណុំរឿងលេខ 55/1996/674/861-864 (‘**Van Mechelen**’), កថាខ័ណ្ឌទី៤៩, ៥១, ៥៥ និង ៧៦ ។ Luca ទល់នឹង ប្រទេសអ៊ីតាលី, ២៧ កុម្ភៈ ២០០១, ពាក្យសុំលេខ 33354/96 (‘**Luca**’), កថាខ័ណ្ឌទី៣៧, ៣៩-៤០; និង A.S. ទល់នឹង ប្រទេសហ្វាំងឡង់, ២៨ កញ្ញា ២០១០, ពាក្យសុំលេខ 40156107, កថាខ័ណ្ឌទី៥៣-៥៤ ។

[62] Unterpertinger, កថាខ័ណ្ឌទី៣៣; Saidi, កថាខ័ណ្ឌទី៤៤; Luca, កថាខ័ណ្ឌទី៤០-៤៣; Delta, កថាខ័ណ្ឌទី៣៦-៣៧; Van Mechelen, កថាខ័ណ្ឌទី៥៥, ៦៣ ។

តែមួយគត់ ឬសម្រាប់ជាកម្រិតមួយនៃការសម្រេច ដើម្បីសម្រេចបាននូវរបកគំហើញខាងអង្គហេតុរបស់ខ្លួននោះទេ។ ទាក់ទិននឹងចំណុចនេះ ផ្ទុយគ្នាពីការអះអាងរបស់ អៀង ធីរិទ្ធ[63] សហព្រះរាជអាជ្ញាបានគូសបញ្ជាក់រួចហើយនៅក្នុងបញ្ជីសាក្សីដែលបានស្នើឡើងរបស់ខ្លួនថា តើសាក្សីណាដែលត្រូវផ្តល់ភ័ស្តុតាងផ្ទាល់មាត់ទាក់ទងនឹងផ្នែកនិមួយៗនៃសំណុំរឿង រួមទាំងទីតាំងឧក្រិដ្ឋកម្មផងដែរ។

## ឃ. ការអះអាងចោទប្រកាន់ចំពោះភាពមិនអាចឲ្យជឿទុកចិត្តបាននៃកំណត់ហេតុសាក្សី

*<u>កំណត់ហេតុរបស់ កសចស</u>*

៣៤- អៀង សារី អះអាងថា កំណត់ហេតុសាក្សីនានាដែលទទួលបានដោយអ្នកស៊ើបអង្កេត កសចស មិនអាចឲ្យជឿបាន និងមិនគួរត្រូវបានទទួលយកជាភ័ស្តុតាងឡើយ ដោយសារមិនបានផ្តល់ឲ្យជនជាប់ចោទនូវសិទ្ធិតទល់គ្នា[64]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាអំណះអំណាងដែលមានលក្ខណៈជាទូទៅទាំងនេះ ដែលបានផ្អែកលើសេចក្តីសន្និដ្ឋានផ្សេងៗដែលបានបដិសេធរួចហើយ ដោយតុលាការនេះ[65] មិនអនុញ្ញាតឲ្យមានការពិចារណាបន្ថែមទៀតឡើយ។ ជនជាប់ចោទមិនអាចយកការវាយប្រហារមុនៗរបស់ខ្លួនមកវាយប្រហារ កសចស ម្តងហើយម្តងទៀត*ដោយគ្មានកំណត់* ហើយរំពឹងថាតុលាការនេះនឹងបំពេញតាមបំណងរបស់ខ្លួននោះ។ តាមរយៈការបង្ហាញ ដែល អៀង សារី លើកយោង និងបកស្រាយខុសស្រឡះនូវសេចក្តីថ្លែងការណ៍ចោទប្រកាន់របស់ចៅក្រម Lemonde ថា គាត់ “ពេញចិត្តដែល [កសចស] ស្វែងរកភ័ស្តុតាងដាក់បន្ទុកជាងភ័ស្តុតាងដោះបន្ទុក” ថាជាការណែនាំដល់បុគ្គលិករបស់គាត់[66]។ តាមពិត អបជ បានសម្រេចហើយថាបើមានសេចក្តីថ្លែងការណ៍ដូចដែលអះអាងចោទប្រកាន់នេះមែន វាមិនមែនស្មើនឹងសេចក្តីណែនាំណាមួយទេ[67]។ អបជ ក៏បាន រកឃើញផងដែរថា អង្គហេតុដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍នេះ មិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីអភិក្រមអនាគតិណាមួយនៅក្នុងកិច្ចស៊ើបសួរទេ[68]។

---

[63] ចម្លើយតបរបស់ អៀង ធីរិទ្ធ, កថាខ័ណ្ឌទី៩ ។

[64] ចម្លើយតបរបស់ អៀង សារី, កថាខ័ណ្ឌទី២៦ ។

[65] សាលដីកាលើពាក្យបណ្តឹងដិតចិត្តរបស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel LEMONDE, សំណុំរឿងលេខ: ០០២/០០៩-១០-២០០៩-អវតក/អបជ(០១), ៩ ធ្នូ ២០០៩ (“សាលដីកាលើពាក្យបណ្តឹងដិតចិត្តទីមួយ”) ។ សាលដីកាលើបណ្តឹងដិតចិត្តរបស់ នួន ជា សុំប្តឹងដិតចិត្តចៅក្រម Marcel LEMONDE, សំណុំរឿងលេខ: ០០២/២៩-១០-២០០៩-អវតក/អបជ(០៤), ២៣ មីនា ២០១០ (“សាលដីកាលើពាក្យបណ្តឹងដិតចិត្តទីពីរ”) ។

[66] ចម្លើយតបរបស់ អៀង សារី, កថាខ័ណ្ឌទី២៦ ។

[67] សាលដីកាលើពាក្យបណ្តឹងដិតចិត្តទីមួយ, កថាខ័ណ្ឌទី២៥; សាលដីកាលើពាក្យបណ្តឹងដិតចិត្តទីពីរ, កថាខ័ណ្ឌទី២០ ។

[68] សាលដីកាលើពាក្យបណ្តឹងដិតចិត្តទីមួយ, កថាខ័ណ្ឌទី១៨-២៦ ។

៣៥- ប៉ុន្តែ ប្រតិចារឹកនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស រៀបចំដោយមេធាវីការពារក្តី អៀង ធីរិទ្ធ ទោះបីជាមានកម្រិតក្តី ក៏វាពិតជាចង្អុលបង្ហាញឱ្យឃើញពីក្តីកង្វល់ស្របច្បាប់ពាក់ព័ន្ធនឹងភាពចប់សព្វគ្រប់ និងភាពត្រឹមត្រូវនៃកំណត់ហេតុសាក្សីរបស់ កសចស មួយចំនួន[69]។ នៅខណៈដែល អៀង ធីរិទ្ធ មិនបានបញ្ជាក់ថាតើវគ្គណាដែលតាមទស្សនៈរបស់គាត់ថា មិនបានបញ្ចប់សព្វគ្រប់ ឬគ្មានភ័ស្តុតាងដោះបន្ទុក នោះយ៉ាងហោចណាស់គេមានគួរយ៉ាងមួយចំនួនដូចខាងក្រោមដែលមានផ្ទុកនូវការខកខាន ឬភាពមិនត្រឹមត្រូវ៖

ក) កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង ម៉ុន បង្ហាញថាសាក្សីរូបនេះបាននិយាយថា "ខ្ញុំបានឃើញ អៀង ធីរិទ្ធ ម្តងម្កាល"។ ប្រតិចារឹករបស់មេធាវីការពារក្តីចំពោះការស្តាប់ចម្លើយសាក្សីរូបនេះវិញអានថា "អៀង ធីរិទ្ធ, គាត់កម្រមកណាស់" និង "ចំពោះ អៀង ធីរិទ្ធ គឺកម្រណាស់ កម្រមែនទែន, ប្រហែលម្តង ដែលខ្ញុំបានឃើញ"[70]។

ខ) យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន់ សុវណ្ណហាន, សាក្សីរូបនេះបាននិយាយថា អៀង ធីរិទ្ធ គឺជា "ថ្នាក់លើ" ក្នុងពេលដែលបើតាងប្រតិចារិករបស់មេធាវីការពារក្តីថា សាក្សីបាននិយាយថា នាងមិនបានដឹងថានរណាជាថ្នាក់លើទេ និងថា អៀង ធីរិទ្ធ បានធ្វើប្រតិបត្តិការនៅថ្នាក់កណ្តាល និងបានទទួលការណែនាំពីថ្នាក់លើ[71]។

៣៦- ទោះបី សេចក្តីសង្ខេបភាគច្រើនត្រឹមត្រូវក្តី ការខកខានដូចបានបង្ហាញជូនខាងលើ ពិតជាផ្តល់ឱ្យមានក្តីកង្វល់ស្របច្បាប់។ ដោយមានការកត់សំគាល់ចំពោះកង្វល់ទាំងនេះ សហព្រះរាជអាជ្ញាសូមសង្កត់ធ្ងន់លើសេចក្តីសន្និដ្ឋានរបស់ខ្លួនថា សាក្សីដែលបានផ្តល់ភ័ស្តុតាងរួចហើយទាក់ទងនឹងទង្វើ និងសកម្មភាពរបស់ជនជាប់ចោទ ឬពាក់ព័ន្ធនឹងផ្នែកដ៏សំខាន់បំផុតនៃសំណុំរឿង គួរត្រូវបានកោះហៅមកបំភ្លឺនៅសវនាការជំនុំជម្រះ។ ប៉ុន្តែដោយសារលក្ខណៈត្រួតគ្នាដ៏ច្រើនរបស់វា កំណត់ហេតុសាក្សីពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម អាចត្រូវបានស្រាវជ្រាវបានយ៉ាងគ្រប់គ្រាន់ តាមរយៈបណ្តុំនៃមធ្យោបាយនានារួមមានការពិនិត្យសាក្សីក្នុងចំនួនមួយដែលមានកំណត់និងការប្រៀបធៀបជាមួយភ័ស្តុតាងដទៃទៀត។ ដូចមេធាវីការពារក្តី អៀង ធីរិទ្ធ បានបង្ហាញ កំណត់ហេតុជាខ្សែអាត់សម្លេងអាចឱ្យមេធាវីការពារក្តី

[69] ចម្លើយតបរបស់ អៀង ធីរិទ្ធ, កថាខ័ណ្ឌទី១៤-១៦ ។

[70] ចម្លើយតបរបស់ អៀង ធីរិទ្ធ, ឧបសម្ព័ន្ធ ក, ឯកសារលេខ E96/2.2, ទំព័រទី១, ៧ ។

[71] ក្នុងឯកសារដដែលដូចខាងលើ, ទំព័រទី៨-១០ ។

ពិនិត្យបានអំពីភាពត្រឹមត្រូវនៃកំណត់ហេតុដែលបានធ្វើឡើងដោយ កសចស។ ជាងនេះទៀត គេគួររំលឹកថា ការស្តាប់ចម្លើយទាំងនេះត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតដែលមិនលំអៀង ហើយគ្មានអ្វីដែលត្រូវឲ្យយោបល់ថា ការភាន់ច្រឡំ ឬការខកខានណាមួយ គឺជាលទ្ធផលនៃភាពលំអៀងប្រឆាំងនឹងជនជាប់ចោទឡើយ។

៣៧- វាជាការសមហេតុផល និងស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋាននៃការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ដែលតម្រូវឲ្យគ្រប់គូភាគីទាំងអស់អនុវត្តដោយប្រុងប្រយ័ត្ន តាមការពិនិត្យឡើងវិញចំពោះសម្ភារៈផ្សេងៗ និងធ្វើការប្រៀបធៀបសម្ភារៈទាំងនោះជាមួយភ័ស្តុតាងផ្សេងទៀត និងធ្វើសេចក្តីសន្និដ្ឋានសមស្រប ដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នៅក្នុងដំណាក់កាលដែលពាក់ព័ន្ធនៃដំណើរការនីតិវិធីភ័ស្តុតាង។ នៅពេលណាសេចក្តីសន្និដ្ឋានបែបនេះបានធ្វើរួច អង្គជំនុំជម្រះសាលាដំបូងអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកប្រតិចារឹក និងកំណត់ហេតុនៃការកែតម្រូវណាមួយចំពោះកំណត់ហេតុសាក្សី។ សហព្រះរាជអាជ្ញាសូមស្នើនូវអភិក្រមដូចតទៅ៖

ក) ប្រសិនជាមាន កំណត់ហេតុជាខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សីដែលនឹងត្រូវកោះហៅមកបំភ្លឺ គួរបានធ្វើប្រតិចារឹកឲ្យរួចស្រេចដោយតុលាការ មុនការផ្តល់សក្ខីកម្មរបស់សាក្សីម្នាក់ៗ (ការណ៍នេះបង្កលទ្ធភាពឲ្យចៅក្រម និងមេធាវីការពារក្តី បានផ្តោតទៅលើការពិនិត្យ និងងាយស្រួលបញ្ជាក់បំភ្លឺអំពីការភាន់ច្រឡំសំខាន់ណាមួយនៅក្នុងកំណត់ហេតុសាក្សី)។

ខ) សម្រាប់សាក្សីដែលនៅរស់ បើមាន ការខកខាន ឬការភាន់ច្រឡំជាក់ស្តែងណាមួយត្រូវបានចង្អុលបានបង្ហាញថានឹងធ្វើឲ្យខូចប្រយោជន៍របស់ភាគី អង្គជំនុំជម្រះអាចបង្គាប់ឲ្យផលិតចេញនូវប្រតិចារឹកនៃការថតខ្សែអាត់ទាំងស្រុង ឬផ្នែកដែលពាក់ព័ន្ធ។

៣៨- ជាការសន្និដ្ឋានចុងក្រោយនេះ អៀង ធីរិទ្ធ មិនបានកំណត់ថា កំណត់ហេតុសាក្សីរបស់ កសចស ទាំងមូល មានភាពមិនត្រឹមត្រូវ មិនអាចជឿទុកចិត្តបាន ឬច្រានចោលភ័ស្តុតាងដោះបន្ទុក។ តាមការពិត កំណត់ហេតុជាលាយល័ក្ខណ៍អក្សរ និងប្រតិចារឹកដែលបានដាក់ជូនដោយ អៀង ធីរិទ្ធ បានផ្តល់សទិសន័យស៊ីសង្វាក់គ្នាយ៉ាងច្រើន ដោយមានភាពមិនស៊ីសង្វាក់គ្នាតិចតួចប៉ុណ្ណោះ។ សំណើសមហេតុផលនានាពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវ ឬការខកខានណាមួយ គួរតែត្រូវបានបំពេញចិត្ត ប៉ុន្តែ

ការណ៍នេះមិនមែននាំឆ្ពោះដោយស្វ័យប្រវត្តិទៅរកលក្ខខណ្ឌតម្រូវដែលថា សាក្សីម្នាក់ៗ និងគ្រប់រូប ទាំងអស់ត្រូវតែកោះហៅឲ្យមកបំភ្លឺនៅសវនាការជំនុំជម្រះទេ។

## *<u>កំណត់ហេតុដែលបានធ្វើឡើងដោយអង្គការផ្សេងៗ</u>*

៣៩- អង្គជំនុំជម្រះគួរបដិសេធចោលគ្រប់ការជំទាស់ទាំងអស់ទាំងមូលតែម្តង ដែលប្រឆាំងនឹងការទទួលយកជាភស្តុតាង នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដែលប្រមូលបានដោយអង្គការពីខាងក្រៅ ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ជាដើម។ ការជំទាស់ទាំងនេះ ត្រូវបានធ្វើឡើងក្នុងន័យទូទៅដែលមិនអាចឲ្យគេធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវទេ[72]។ អនុលោមតាមវិធាន៨៧(១) ភស្តុតាងទាំងអស់ត្រូវបានទទួលយក និងដូចដែលបានបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានរបស់ កសព ករណីយុត្តិសាស្ត្រអន្តរជាតិ អនុញ្ញាតឲ្យទទួលយកកំណត់ហេតុសាក្សីដែលបានប្រមូលដោយបុគ្គលផ្សេងក្រៅពីមន្ត្រីតុលាការ[73]។ ប្រសិនបើ មេធាវីការពារក្តីមានបំណងចង់តវ៉ាចំពោះកំណត់ហេតុរបស់បុគ្គលណាម្នាក់ ពួកគេគួរតែរំពឹងថា នឹងធ្វើការជំទាស់របស់ខ្លួនឲ្យបានជាក់លាក់ និងផ្តោតទៅលើទឡ្ហីករណ៍ច្បាស់លាស់សម្រាប់ការច្រានចោល ដូចជាអនុវិធាន៨៧(៣) និងគោលការណ៍អន្តរជាតិដែលពាក់ព័ន្ធ។ លើសពីនេះ កង្វល់ណាមួយចំពោះការពិតដែលថា កំណត់ហេតុត្រូវបានធ្វើឡើងដោយគ្មានសម្បថ អាចនឹងត្រូវបានលើកឡើងនៅពេលធ្វើការពិចារណាអំពីតម្លៃជាភស្តុតាង និងភាពអាចជឿទុកចិត្តបានរបស់វា និងការអនុម័តនីតិវិធីផ្សេងៗដូចបានស្នើក្នុងសេចក្តីសន្និដ្ឋានរបស់ កសព រួមទាំងលទ្ធភាពអាចធ្វើបាននៃការស្វែងរកការបញ្ជាក់បំភ្លឺជាបន្តបន្ទាប់។

## III. សេចក្តីសន្និដ្ឋាន

៤០- ជាសង្ខេប ក្នុងខណៈដែលអង្គជំនុំជម្រះត្រូវថ្លឹងថ្លែងអំពីសិទ្ធិរបស់ជនជាប់ចោទ ដើម្បីពិនិត្យសាក្សីជាមួយនឹងកាតព្វកិច្ចដើម្បីថែរក្សាតុល្យភាពរវាងភាគី និងការធានាចំពោះការងារគ្រប់គ្រងសវនាការជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស នោះនីតិវិធីជាធរមានមិនបានចែងឲ្យមានយន្តការឲ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវគោលដៅនេះឡើយ។ ប្រសិនបើត្រូវបកស្រាយទៅតាមអ្វីដែលបានស្នើឡើងដោយជនជាប់ចោទមែន នីតិវិធីទាំងនោះនឹងនាំឲ្យមានការរំលោភទៅលើវិធាននានារបស់ប្រទេសនិងបទដ្ឋានអន្តរជាតិ ហើយនឹងធ្វើឲ្យសវនាការជំនុំជម្រះក្តីនេះមិនអាចគ្រប់គ្រងបាន។

[72] សូមអាន ជាឧទាហរណ៍ ចម្លើយតបរបស់ អៀង សារី, កថាខណ្ឌទី២៣ និង ចម្លើយតបរបស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៤៧ ។

[73] សេចក្តីសន្និដ្ឋានរបស់ កសព, កថាខណ្ឌទី២២(ឃ) ។

អាស្រ័យហេតុដូច្នេះ គឺជាការសមស្របដែលត្រូវស្វែងរកគោលការណ៍ណែនាំពីវិធានអន្តរជាតិ ដូចមានចែងនៅក្នុងមាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែ៖

ក) អនុម័តអភិក្រមដូចបានស្នើឡើងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ កសព ។

ខ) ដើម្បីដោះស្រាយកង្វល់ដែលកើតចេញពីចម្លើយតបរបស់ អៀង ធីរិទ្ធ, ១) បង្គាប់ឲ្យធ្វើប្រតិចារឹកលើកំណត់ហេតុខ្សែអាត់សម្លេងដែលមាននៃចម្លើយសាក្សីទាំងឡាយ ដែលត្រូវកោះហៅមកបំភ្លឺ និង ២) បង្គាប់ឲ្យធ្វើប្រតិចារឹកពេញលេញ ឬមួយផ្នែកចំពោះកំណត់ហេតុជាខ្សែអាត់ណាដែលភាគីបង្ហាញឲ្យឃើញថា កំណត់ហេតុសាក្សីពាក់ព័ន្ធមានផ្ទុកនូវការភាន់ច្រឡំ ឬការខកខានសំខាន់ជាក់ស្តែងដែលនាំឲ្យខូចប្រយោជន៍ របស់ភាគីណាមួយ។

គ) មិនបើដូច្នោះទេ បដិសេធចោលអំណះអំណាងទាំងឡាយដែលបានលើកក្នុងចម្លើយតប៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |